# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ថាត ហៅ ស៊ឹមហោ I03003
## សម្ភាសន៍ជាមួយ ថាត ហៅ ស៊ឹមហោ ជាម្ចាស់ប្រវត្តិរូប
## នៅភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ
## សម្ភាសន៍ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៣
## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា និង ស៊ុ ឃិន

ហោៈ បើនិយាយទៅថា រៀបជាមួយនឹង..? កាលពីដើមនៅបើថាប្រវត្តិធ្វើទាហានឲ្យខ្មែរក្រហមនេះ ឯងក៏បែកគ្នានៅកំពង់សោមនេះវិញ ។ខ្ញុំក៏ឡប់មកភ្នំពេញនេះវិញ ។ ឆ្នាំ៧៥ យើងក្រោយរំដោះទីក្រុងភ្នំពេញ ។ជម្លៀសប្រជាជនចេញពីភ្នំពេញចឹងមក ។ ក៏សម្រាកនៅទីក្រុងភ្នំពេញ ។ បានគេបែងចែកកកម្លាំងមួយចំនួននៅភូមិភាគខត្តរ ។ គេដកខ្ញុំក្តាប់មិនសូវបាន ព្រោះខ្ញុំវាក្រោមដែរ ។ គេថាទៅនៅកំពង់សោម២វរសេនាតូចទៅនៅណោះ ។ ដល់ទៅនោះ វាច្រឡូកច្រឡំបញ្ចូលគ្នារហូតដល់ឆ្នាំ៧៦ ដូចបានជម្រាបម៉ិញគេរៀប គេរៀបប្រពន្ធអីយប់នោះ ខ្ញុំនេះគេត្រូវដកកម្លាំងមួយចំនួនឡើងមកនៅភ្នំពេញវិញ ។ ចឹងទៅក៏គេដឹងថាហេតុផលនេះ ត្រូវបែកគ្នាគេធ្វើម៉េច គេសរសេរសំបុត្រមួយឲ្យយើង មកជួបគេខ្លាចគេ គេថាលាក់ការណ៍ចឹងដែរ ឲ្យខ្ញុំទៅជួបគេ ។

ដារ៉ាៈ ជួបពីណា?

ហោៈ ជួបនៅកំពង់សោមដែលនៅណោះទាំងអស់គ្នាយប់នោះខ្ញុំត្រូវចេញហើយម៉ោង៨អីគេត្រូវដកកម្លាំងមួយចំនួនដែលត្រូវដកមកណោះ ។គេត្រូវបែកគេសរសេរសំបុត្រមក ប្រធានវរសេនាតូចមកប្រាប់ខ្ញុំថា នែ មិត្តថាត សម្លាញ់បងថាតឯងឲ្យទៅជួបនៅវេលាម៉ោង៧យប់កុំខាន ។ ក៏ខ្ញុំនោះនិយាយទៅខ្ញុំអត់មានឋានៈគេ ដូចនៅក្នុងប្រវត្តិរូបនឹងគេ ខ្ញុំជឿថាតាំងពីនៅរៀននោះជាមួយព្រោះអាយុស្មើគ្នា ខ្ញុំនិងគេមិនសូវប្រកាន់សិទ្ធិអំណាច និយាយត្រង់ ។ ទៅក៏ជួបគ្នា ថាបានស្គាល់ហើយថាមុននឹងបែកគ្នាចង់ឯងទៅនៅជាមួយ ។ ប៉ុន្តែមិនដឹងធ្វើម៉េច ព្រោះកាលៈទេសៈមិនអាចផ្តល់ឲ្យយើងនៅជួបជុំក្នុងភូមិមកចង្កោមជាមួយនៅជុំគ្នាគឺអត់បាន គឺអង្គការគេចាត់តាំង ។ សម័យនោះហៅថាអង្គការចាត់តាំង ។ គេឲ្យ

ស្គាល់គ្នាហើយ ។ប្រពន្ធគ្នាទើបរៀបគ្នា មិនហ៊ានស្ដីគ្នាព្រោះខ្មាស់ទើបរៀបថ្មី។ បើប្រពន្ធខ្មោចឈ្មោះ លំអាន នោះសុភាពណាស់មនុស្ស បើតាមនិយាយហៅថាចាស់ទុំនយោបាយខ្មាសអៀន។ ដួសបាយអីចឹងទៅ ខ្ញុំហូបហើយ ខ្ញុំនៅនិយាយសំណេះសំណាលគ្នា ហើយខ្ញុំអត់បានចាំប្រវត្តិថាភូមិស្រុកកំណើតគេនៅណាណី។ ខ្ញុំមិនទាន់បានសួរនាំផងមិនបានចង់ក្រងចាំទេ។ ប៉ុនបានស្គាល់ចរឹកថាចរឹកគេល្អណាស់សុភាពជានារីថា ចាស់ទុំចិត្តគំនិតមិនអ្នកឡេះលោះទេ ក៏បែកគ្នាទៅ។ កាលខ្ញុំដឹបូងខ្ញុំមកនៅភ្នំពេញកាលឆ្នាំ៧៦ ។ មកដល់ភ្នំពេញគេឲ្យខ្ញុំមកនៅប្រាំងចំរេះម្ដុំគីឡូលេខ៦ ។ នៅនោះឯងគេឲ្យលីសែងបញ្ចូលកម្មករហឺ!មនុស្សខ្ញុំតាំងពីដើមមិនដែលអ្នកលីអ្នកសែងរែកពន់ធ្ងន់អី។ បើមនុស្សនៅតែរៀនរហូតដល់សម័យនោះឯងក៏ពេញអាយុដែរថា១៨ទៅ១៩ឆ្នាំវាពេញល្មម ។ ក៏គេឃោសនាបញ្ចូល ។ ក៏នៅធ្វើកម្មកររហូតបានដកពីនោះមកបានគេឲ្យខ្ញុំមកទីក្រុងភ្នំពេញ ។ ទៅនៅម្ដុំតាខ្មៅ ។

ដារ៉ា: នៅតាខ្មៅ?

ហោះ: បាទ! ខ្ញុំទៅនៅតាខ្មៅបានប៉ុន្មាននៅប្រហែលជា ។ អូ និយាយនេះរំលងហើយ កាលមកពីកំពង់សោមមកនៅវត្តខណ្ឌលោមដំហានដំបូង ។ និយាចេះតែភ្លេចហ្នឹងនិយាយពីកំណើតពីឡប់មកពីកំពង់សោមវិញមកនៅវត្តខណ្ឌលោម ។ នៅវត្តខណ្ឌលោមគេឲ្យមកធ្វើការនៅផ្សារថ្មី។ អត់ទាន់ស្គាល់ទីក្រុងភ្នំពេញផង មិនដឹងណាផ្សារអូឫស្សី។ គេជូនទៅម្ដងទៅ គេថាស្នែកឡើងទៅធ្វើកន្ទែងដើម អាផ្ទះលេខ៤៩ វិថីកសង្កាត់វិថីសេរីភាពចឹងទៅ។ មិនដឹងណាវង្វេងកណ្ដាលទីក្រុងភ្នំពេញ ព្រោះអត់ដែលដឹងដែរ។ ព្រោះមនុស្ស នៅស្រែដល់មកនៅភ្នំពេញអត់ទាន់ចំណាំបានមកដល់ភ្លាម ។ វង្វេងដើរឡិកឡក់ដើរសួរគេ គ្នាម៉ាហ្វូង ដើរសួរចុះសួរឡើងអត់ហ៊ានសួរនារីទេ ដែលគេលក់ដូរកន្ទែងដែលដាក់ផ្សារបរទេស។ លក់ពួកវាគេលាក់ការណ៍របស់វាដែរ ។ វាមានធ្វើកន្ទែងផ្សារម៉ាកន្ទែង ផ្សារថ្មី។

ឃិនៈ អន្តរជាតិ?

ហោះ: បាទ ដូចថាបរទេសមកវាដាក់សំលៀកបំពាក់មកហើយលក់បន្ទែលក់សាច់លក់ឈាមចឹងទៅវាធ្វើតែម៉ាកូនកន្ទុមប៉ុណ្ណឹងឯង។ ចឹងទៅនឹកឃើញថាមិនហ៊ានសួរគេទេ ក៏សួរតាតៃកុងឡានមួយ។ ព្រោះឡាននោះវាខូច ក៏សួរទៅ បងស្គាល់ផ្ទះលេខ៤៩ទេ ផ្លូវច្រក ផ្លូវតូច

ចូលផ្ទះនោះកន្លែងខ្ញុំធ្វើការ ។ អ៊ី កន្លែងនារីឈរលក់ឥវ៉ាន់ខាងក្រោយហ្នឹងតិច ប្អូនឯងដើរទៅតិចទៅចូលទៅចំៗ ។បានគេបំបែកពីនោះបានមកនៅប្រាំងចំរេះធ្វើការនៅគីឡូលេខ៦ ។

ដារ៉ា: ចុះនៅកន្លែងផ្សារថ្មី ផ្ទះលេខ៤៩ហ្នឹង នៅធ្វើអីនៅហ្នឹង?

ហោះ: គេឲ្យដូចថា រៀបឥវ៉ែឥវ៉ាន់ កំប៉ិចកំប៉ុក ខ្ទប់ចង់នៅហ្នឹង អត់បានយូរទេនៅហ្នឹងនៅខណ្ឌលោមបណ្ដោះអាសន្នសម្រាប់គេរៀបចំចាត់តាំងបំបែកពីគេ ។

ដារ៉ា: កាលហ្នឹងនៅឆ្នាំណា?

ហោះ: ឆ្នាំ៧៦ហ្នឹង កាលខ្ញុំមកចេញពីកំពង់សោមមកឆ្នាំ៧៦ខែ៥ខែ៦ ចេញពីកំពង់សោមមកបានមកដល់ណោះ គេមិនទាន់បំបែកគេរកកន្លែងឲ្យនៅ ។ ឲ្យទៅធ្វើការបណ្ដោះអាសន្នសិនគេបញ្ចូលកម្មករគេកម្មករលីសែង ។ ដល់ចឹងទៅយូរអង្វែងបាននៅគីឡូលេខ៦បានលីសែង ។ លីសែងបានមួយរយៈទៅបានគេដកកម្លាំងមួយចំនួន គេថាដកមួយកងមួយ កងអនុសេនាតូចឲ្យទៅតាខ្មៅណោះ ខាងចាក់អង្រែ ទៅខាងរោងចក្រ ។ រោងចក្រអីទេទៅដល់គេថា នែពួកមិត្តឯងនេះនៅដេកម៉ុំខាងណោះស៊ីងព្រែកត្នោតយើង ខ្ញុំនៅខាងណោះឆ្លងស្ពឹងខាងណោះមានរោងចក្រគ្រីបសំឡីគ ។ សំឡីនោះមិនដឹងគេវែមកពីណាទេ ស្អាតចឹងទៅគេបញ្ជូនទៅកន្លែងរោងចក្រហ្នឹងទៅ ។ អានោះពុម្ពវា១០០គីឡូជាន់ញាត់ៗដាក់ឲ្យណែនទៅបានដាក់អាខ្សែក្រវ៉ាត់វាទៅ បានវាវៃផ្លាកលេខ ដឹកចេញ ទៅក្រៅប្រទេស ។

ដារ៉ា: ចេញទៅខាងណា?

ហោះ: ដឹកទៅកំពង់សោមវិញ ។ ឮថាដឹកពីកន្លែងរោងចក្រមកដឹកមកដាក់នៅវ៉ារទេះភ្លើងយើងរួចបានច្រើនចឹងទៅបានចេញទៅកំពង់សោម ។ ទៅមុនដំបូងជំនួយអង្ករនៅកំពង់សោមចិនគេជំនួយមក ជំនួយអង្ករគ្រឿងដែក ចបប៉ែល ថ្នាំសម្លាប់សត្វល្អិត ដល់យើងមានតែសំឡីគ ហើយនឹងកៅស៊ូយើង មុនដំបូងកៅស៊ូស្អុយគ្រាន់តែចាក់ដុំចឹងទៅ ។ ខ្ញុំនៅនោះបានជិតម៉ាឆ្នាំ គិតទៅស្លាប់កុមារអស់ពីរនាក់ ។

ដារ៉ា: ស្លាប់រឿងអី?

ហោះ: ស្លាប់នោះ ស្ងាននេះឯង ក្មេងនោះកូនភ្លោះទៀត កូនកម្មករ ។ កម្មករនោះគេហៅថាកម្មករចាស់ទៅធ្វើការនៅរោងចក្រនោះឯង ។ ដល់នេះគេបញ្ចូលកម្លាំងទៅបម្រើការងារពួកខ្ញុំ ។ គេបំបែកម្ដាយឪពុកចេញទុកកូនហ្នឹង ។ កូនហ្នឹងប្រហែលជាអាយុ កូនភ្លោះ កូន

ចិនស្អាតដល់ហើយ មុខដូចគ្នា ស្រណោះដល់ហើយ គេនៅកងផ្សេងៗ វាចេះដេរបាវ យើងគឺម៉ាដុំៗប៉ុនៗណោះ ខ្ញុំនៅសន្កត់សំឡឹកខាងក្រោម ឯគ្រឿងម៉ាស៊ីនវាប្រទីសប្រទាស ហើយខ្សែពានយោងពីលើពីក្រោម មានម៉ាស៊ីយើងធម្មតាអី ម៉ាស៊ីនយើងម៉ាទីក្រុងភ្នំពេញ ចាប់តែខ្សែកាបសោះ ទម្រាំអាបិទកុងតាក់អាធំនោះ មនុស្សណោះស្លាប់បាត់ៗ កាលនោះ វាសួររកកាំបិតកាត់ខ្សែដេរបាវៗ ក៏វាដាក់ខ្សែដេសនឹងដៃដើរទៅ ពេលវាដើរទៅម៉ាស៊ីន កំពុងដើរហើយខ្សែពានពីលើពីក្រោមមិនចេះតិច ហើយភ្លៅអាដែកហ្នឹងកំពស់ពីក្តាប៉ុណ្ណេះ នៅលើ វារុំអាហ្នឹង ដូចយើងចងកដៃចឹង វាទ្រឹងៗទៅ បាក់ក បាក់អានេះខ្ទេចទម្រាំទាក់ អាខ្សែពាននោះរបូតមានជួយអីកើតរបូត ទម្រាំកាត់ដេសនោះបានយកមកៗ បានចេញ មកឈាមដល់ហើយៗ ដាក់ឡានមក ដល់ត្រឹមមុខពេទ្យចិនដាច់ខ្យល់ស្លាប់ៗ ខ្ញុំអាណោច អាធមស្លាប់អាបងនៅអាប្អូនៗ

យិនៈ ក្មេងអាយុប៉ុន្មានឲ្យធ្វើការដែរ?

ហោៈ ក្មេងនោះកុមារប្រហែលជាអាយុ១២ទៅ១៣ឆ្នាំៗ

យិនៈ វាប្រើឲ្យធ្វើការអារដែរ?

ហោៈ បាទ! វាបញ្ចូលជាមួយចាស់ជាមួយគ្នាទៅៗ ខ្ញុំអណោចអធមមែនទែន ប៉ុនរោងចក្ររបស់ ក្រែលដែរ គេដកខ្ញុំមកណោះទៅ គេបញ្ចូលកម្លាំងថ្មីស្លាប់មនុស្សធំអស់១ទៀតទៅៗ ប៉ុន នៅក្នុងកងខ្ញុំអត់អីៗ

ដារ៉ាៈ ចុះកាលនៅប្រាំងចំរេះគេឲ្យពូធ្វើអី?

ហោៈ ខ្ញុំធ្វើមេក្រុមៗ

ដារ៉ាៈ មេក្រុមអីគេ មេក្រុមទទួលខុសត្រូវខាងអីគេ?

ហោៈ កម្មករ ដូចថាក្នុងមួយកងអនុសេនាធំចេះ វាមាន៣កងអនុសេនាតូចៗ ក្នុងមួយអនុសេ នាតូចមាន៣ក្រុមចឹងទៅៗ ខ្ញុំប្រធានក្រុមៗ

ដារ៉ាៈ នៅជាអ្នកធ្វើការ ឬនៅជាយោធា?

ហោៈ អត់ទេ នៅក្នុងកម្មករបើគេរើសពីចង្កោមហ្នឹងៗ

ដារ៉ាៈ ពីចង្កោមរចនាសម្ព័ន្ធយោធាហ្នង?

ហោះ   បាទ! នោះឯងរចនាសម្ព័ន្ធយោធាហ្នឹង ប៉ុនជាកម្មករទេ។ វាគ្រប់គ្រង។ ហើយធ្វើការនោះធ្វើម៉េចឲ្យវិលដូចម៉ាស៊ីន។ ដូចថាខ្ញុំចាប់ផ្ដើមកម្លាំងខ្ញុំចូល២០០ចេះទៅ។ ម៉ោពីម៉ោង ៧យប់ទល់ម៉ោង ៩ មានវេនគេមកដូរខ្ញុំ។ ខ្ញុំចេញមកសម្រាក។ ពីម៉ោង៩ទល់ម៉ោង៣ អាពីម៉ោង៣ មកដូរចឹងទៅ ទៅទល់ពីម៉ោង៧ព្រឹក។ អាម៉ោង៧ព្រឹក ដូរវិលចឹងហ្នឹងគឺអត់ឈប់។ អ្នកណាចុងវេនម៉ោង៣កំពុងតែសម្រាកទៅដាស់ ផងុយនោះ មួយខែ៣០ថ្ងៃជាប់ចឹងហ្នឹងរាំនៅជាប់នឹងខ្លួន។ គេឲ្យខ្ញុំទៅនៅប្រាំងចំរេះ អ៉ាសទៅនៅតាខ្មៅទៅនៅធ្វើម៉ាស៊ីនបានម៉ារយៈចឹងមក បានគេត្រឡប់ដកមកប្រាំងចំរេះវិញទៀត ខ្ញុំចេះឆ្វល់ឡប់ទៅឡប់មកមកកន្លែងដើមទៀត។ ដល់មកនៅចឹងគេចាប់ផ្ដើម ដូចខ្ញុំជម្រាបម៉ិញពីការចាប់លោក កុយ ធួន។ លោក កុយ ធួនកាលពីដើមគាត់ជាប្រធានភូមិខត្តរយើងប៉ុនដោយឡែកក្រោយមកគេបញ្ចូលក្នុងជួររដ្ឋមន្ត្រីក្នុងរបស់ខ្មែរក្រហម។ ហឺ! គាត់រដ្ឋមន្ត្រីខាងរកសួងពាណិជ្ជកម្មក្រៅប្រទេស។ ស្រាប់តែគេចាប់គ្រឹមចេញចេះទៅ ក៏ខ្ញុំចេះឆ្ងល់ម៉េច ចេះដល់យូរៗគេថាបាត់។ មុនដំបូងមិនមែនចាប់ភ្លាម ដល់ចាប់ កុយ ធួន ចឹងហើយអាវុធក៏ត្រូវរកផ្ទុះ។ ប៉ុល ពត គេដឹងផែនការ។ កាលណោះរកផ្ទុះអាវុធ។

ដារ៉ាៈ   រកផ្ទុះមែនកាលហ្នឹង?

ហោះ   អត់ទាន់បានផ្ទុះទេ កាលហ្នឹងចាំខ្ញុំជម្រាប ដូចទាហានដែលនៅក្នុងកងពលចឹងគ្នាអត់ដឹងខ្លួនទេគេឲ្យរកក្ដាអីទៅវៃដូចសង្គ្រាមចឹង មិនដឹងវៃអាណាបើសុទ្ធតែមិត្តគ្នាឯង។ ដល់ចឹងមិត្តគ្នាឯងចឹងមិនដឹងវៃអាណា។ គ្រាន់ថាកូនខ្លាចមេណាស់ គេឲ្យរៀបកាំភ្លើងអាធំជ្រុងនេះ បើអាពោចិនតុងផ្ទុះពីព្រលានយន្តហោះ អាប្រាំងចំរេះក៏បុកទៅនេះ អាខាងណោះក៏បុកពីណោះមកចូលទីក្រុងភ្នំពេញ។ ខ្ញុំអត់ដឹងទេ ដល់ក្រោយមកគេចាប់ កុយ ធួន ចឹងទៅ គេរួចអស់ពីរំសាយបន្តបន្ទាប់ចាប់ពីមេធំបន្ទាប់មកបានកងពល បានកងពល មកបន្តៗវរសេនាតូច អនុសេនាធំរហូតដល់ប្រធានកងធំក៏វាអស់អាលឹងមេ ក៏ផ្ដាំដៃអត់មានអាណាដឹកនាំធ្វើការក៏ឡេឡឺមិនដឹងទៅណាមកណាយូរៗភ័យពួកខ្ញុំនៅតែមេក្រុមចេះឯង នៅស្មោងមានពីរនាក់នៅកំពង់ធំម្នាក់។ បើមនុស្សវាព្រោងព្រាតរកកាប់រកចាក់គ្នាកាលណោះពេលនោះ ខ្ញុំភ័យនឹកឃើញថាម្ដងនេះហើយ ឥឡូវបើយើងរត់ ក៏យើងមិនដឹងរត់ទៅណា រត់មកស្រុកមិនដឹងទៅពឹងអ្នកណា។ បើមកសហករណ៍គេសម្លាប់ ចឹងមានតែយើងរត់ទៅទី

ក្រុងភ្នំពេញវិញព្រោះនៅប្រាំងចំរេះ ។ បើថាម៉េចទៅជួបមេធំទៅគ្រាន់ បើយើងអត់ដឹងអំពីកិច្ចការគេក្បត់ជាតិឬមិនក្បត់ជាតិអត់ដឹង ។ កាលហ្នឹងនោះដឹងហេតុផលម៉ាចំណែកហើយកាលនោះភ្ញាក់ខ្លួនថា អូអត់ស្រួល ដល់គេចាប់ហើយគេរំសាយបានម៉ាថ្ងៃគេមកប្រមូលកម្មករហ្នឹងយកទៅកន្លែងផ្សារចាស់វត្តភ្នំគេប្រជុំ ។ គេប្រជុំផ្នែកពាណិជ្ជកម្មកម្មករដែលនៅប្រាំងចំរេះប៉ុន្មានចិនទៅប៉ុន្មាននាក់នៅវរសេនាតូចចិន គេប្រជុំហើយគេជ្រើសតាំងថ្មី ។ ជ្រើសតាំង គេថ្កោលទោសថានែ កុយ ធួន ក្បត់ជាតិចេះៗ ឯកសារចេះៗ ចាប់ទម្លុះចាប់មនុស្សប្រកបាវទម្លាក់ទឹកនៅជ្រោយចង្វារនេះទៅ សកម្មភាពនេះគឺអត់ល្អទេ ។ ប៉ុន្តែការពិតដែលដឹងក្រោយនេះគឺមាន ហ៊ូ នឹម និង កុយ ធួន កាលដែលរំដោះភ្នំពេញហើយគាត់ជំទាស់អំពីការជម្លៀសចេញប្រជាជនមកក្រៅហើយបំបិទការចាយលុយគាត់ប្រុងរៀបផែនការជាមួយកុយ ធួន វៃ ប៉ុល ពត វិញ ។ តែវៃអត់បានវាបែកការណ៍ចាប់កុយ ធួន ហ្នឹង ។ គាត់យកមាសប្រាក់កប់ទៅបើកាលណាវៃឈ្នះ ប៉ុល ពត រៀបចំផ្សារផ្សេង ចាយលុយទៅវៃ ។ ឲ្យដូចពីសម័យមុន គម្រោងការគាត់ ។

ឃិនៈ ចឹងបោះពុម្ពប្រាក់ហើយចឹង?

ហោះ ដល់ចឹងទៅវាបែកការចាប់ កុយ ធួន មេក្លោងបានមុន ពីក្រោមគេវៃរាប វៃរាបគេចាប់កងទ័ពគេចាប់ទាំងអស់ទុកតែប្រធានក្រុមៗទេ ដូចខ្ញុំដូចអីដែលអត់ដឹងអី ។ ទុករំសាយចោលអស់អាលឹង ដល់រំសាយចោល គេជ្រើសថ្មី យកសុទ្ធតាំងពួកនិរតីមក ។ យកពីពួកសហករណ៍ ដឹងម៉េងអី យកមកគ្រប់គ្រងឯងពីតាំងពីអើយណាណីក្បាលស្រកាក្រាស់ហើយខ្ញុំថាគេធ្វើអីធ្វើទៅធ្វើតែរាស្ត្រវាស្រួលជាងស្រណុកឲ្យគេប្រើ ។ គេក៏គេថ្កោលទោស ក្បត់ជាតិអីអាណា«ខ្មែរសេអ៊ីអា ខ្មែរកាសេបេ»គឺយួនលេបទឹកដីគេដាក់ចេះ ។ ហើយកុយធួននេះគេថាខ្មែរសេអីអា ខ្មែរអាមេរិកាំង ។ ខ្មែរស្អីខ្មែរសូវៀតខ្ញុំភ្លេចហើយ ។

ដារ៉ាៈ កាសេសបេ?

ហោះ ហ្នឹងហើយ កាស្សេបេ ។ ខ្មែរសូវៀតមានចឹង ។ ដែលមានពាក់ព័ន្ធខាងខ្មែរសោភឹម ដែលកែ ពក ដេញចាប់ ។ គាត់បាញ់ខ្លួនគាត់សម្លាប់ ។ តាសោភឹម គាត់តស៊ូបាន បើនិយាយទៅខ្ញុំរត់ទៅ ។ និយាយនេះកាត់ថា រត់ចូលព្រៃឡើងទៅភ្នំឱរ៉ាល់អីទៅឯងដេរថា អាហេងសំរិន នេះក្បាលយួនខ្លួនខ្មែរ ។ ប៉ុនសម្តេចហ៊ុន សែន អីមិនទាន់មានឈ្មោះទេ កាល

ហ្នឹង មានតែ ហេង សរិន ជាស៊ីម ។ ពូឈ្មោះហើយ ។ អាមួយប្រធានក្រុមខ្ញុំវាអា ហេង សរិន នេះមេចោរហ្អែងដឹងទេ នៅជិតស្រុកអញ ។ នៅជិតស្រុកយួន វាថា អានោះឈ្មោះ ណាំ វាប្រធានក្រុមខ្ញុំអាមេខ្មែរក្រហម ឥឡូវវារត់ទៅព្រៃហើយ ។ ដឹងអី អញអត់ដឹងអីដែរ ។ គេណែនាំថា គេថាម៉ែឪយើងបើមិនរត់ឡើងលើភ្នំយើងធ្វើទាហានឲ្យខ្មែរក្រហមបើចាប់ម៉ែយើងឪយើង គេបន្តាប់ថានេះដែកគោលម៉ាតឹកកន្ទះវៃភ្លាប់នៅនេះ ។ បើយើង វាចាប់បានវាវាពុះ ហើយអាំង ម៉េចវាថាកុំឲ្យកំពប់គេអុងយីចឹងម៉េចកើត បើមិនរត់តាមវា កាលហ្នឹងគិតរត់គិតទៅឆោតៗឆោតមែនទែន ។ បានបេះទៅនិយាយសារដើមវិញ ។ គេចាត់តាំងអីរួចទៅមិនបានរយៈណាផង ពួកអ្នកដែលគេចាត់តាំងធ្វើជាប្រធានក្រុមប្រធានកងតូចប្រធានកងធំថ្មីនេះទៅនៅទីក្រុងភ្នំពេញ អានោះនៅផ្សារចាស់ ។ អត់ទាន់ឲ្យហូបបាយទេគេថានែ ជនាន់កុយ ធួន គេទិញម្សៅពីបរទេសនៅសល់ច្រើនឥឡូវឲ្យហូបនំប៉័ងក្នុងម្នាក់ម៉ាពេលឲ្យហូបមួយ ។ ល្ងាចហូបមួយព្រឹកហូបមួយ ។ វៃជួងម៉ឺងទៅនំប៉័ងមួយហូបជាមួយសម្ល ខ្ញុំនៅនោះត្រង់កន្លែងនៃខ្ញុំនៅមុំទូតហ្នឹងឯងផ្ទះខ្ញុំម៉ាជួរហ្នឹង ។

យិនៈ មានសម្លទេ?

ហោះ សម្លការី ។ បើអ្នកណាឈឺគ្រុនសម្រាកពេទ្យហ្នឹងកន្លែង អាហ្នឹង គេឲ្យយកបបរ យកអីទៅឲ្យនៅហូបចោះ បើថាអ្នកជាអត់ឲ្យហូបនំប៉័ង អត់ឲ្យហូបបាយ ហូបបបរទេ ។ នំប៉័ងម៉ាពេលមួយ ។ បានឡប់ពីនោះមកចាត់តាំងពីនោះមកបាត់មនុស្សអស់អាលីង គេចាប់យូរៗបាត់មួយ យូរបាត់ពីបាត់ចុះបាត់ឡើងក៏ខ្ញុំក៏អត់ហ៊ានសួរដេញដោលទៀត ហើយម៉េចៗទេតែបាត់ៗហើយ ។ បានរៀបចំចាត់តាំងម៉ាសារទៀតហើយ ។ ចាត់តាំងម៉ាសារទៀត បានខ្ញុំនេះឡើង យកខ្ញុំនេះឡើងជាប្រធានកងអនុសេនាធំលើគេដែរ ។ បានគេដកពីផ្សារចាស់ទៅនៅវត្តទួលទំពូងនោះទៅទាល់វៀតណាមចូល ។

ដារ៉ាៈ នៅឆ្នាំណាដែលពូត្រូវបានតែតាំងជាអនុសេនាធំ?

ហោះ ឆ្នាំ៧៨ ។ ឆ្នាំ១៩៧៨ ។ ខ្ញុំនៅមុំទួលទំពូង ជួយ....?អស់ទៅ គេបង្កើតទៅដល់ពេលនោះយកសំឡេងឯងម៉ាទៀត តែនេះគេដេញដោលនិយាយពីការងារ ការងារគឺ កំណត់ធ្វើការក្រោយពីម៉ោង៨ស្រោចទឹកបន្លែ កាលភ្លឺហើយធ្វើហើយ ម៉ោង៧ ការងារស្នូលគេហៅការងារស្នូលគឺការងារលីសែងឬអ្នកណាត្រូវលីសែងៗអ្នកណាត្រូវសរិតសំរាំងនៅ

កន្លែងនោះសរិតសំរាំងនៅនេះចំការម្ទេស សរិតសំរាំងអនុផលដែលយកតាមភូមិភាគនានាមក ។ ហើយមុខសញ្ញាខ្ញុំគេឲ្យគ្រប់គ្រងម៉ាស៊ីន១០គ្រឿង ។ ម៉ាស៊ីនវៃសំឡីគហ្នឹងនៅវត្តទួលទំពូងហ្នុង ។

ដារ៉ាៈ នៅកន្លែងសំឡីគអ្នកណាគ្រប់គ្រង?

ហោៈ ម៉ាស៊ីនវៃសំឡីគ ខ្ញុំអ្នកគ្រប់គ្រង នៅវៃសំឡីគគឺខ្ញុំ ។

ដារ៉ាៈ ខ្ញុំនិយាយថាប្រធាននៅកន្លែងហ្នឹង?

ហោៈ កន្លែងនោះ អូ! នៅពីលើខ្ញុំប្រធានមន្ទីរគេ នារីនៅខាងនិរតី ។

ដារ៉ាៈ ឈ្មោះអី?

ហោៈ ឈ្មោះមិត្ត ផាត ។

ដារ៉ាៈ មិត្តផាតឈ្មោះដូចពូដែរ?

ហោៈ បាទ! នៅខាងនិរតី ទើបអាយុ១៨ ប្តីគេប្រធានធំនៅខាងផ្នែកពោធិចិនតុង ប៉ុនខាងខត្តរយើង ហើយប៉ុនប្រពន្ធនោះនៅនិរតី ។ ប៉ុនលើមិត្តផាតប្រធានមន្ទីរនោះ គឺប្រធានក្រសួងមានតាហុង លើតាហុងទៀតគឺមានតាវិទ្ធ ។ តាវិទ្ធនោះមេធំ បន្ទាប់ពីរដ្ឋមន្ត្រីមក ។ ចឹងមានគេបន្តបន្ទប់គ្នាមក ។ តាវិទ្ធ នោះគ្រប់គ្រងទាំងអស់ទាំងក្នុងទាំងក្រៅប្រទេស ។ ក្រោយពីចាប់តាញ៉ែម តាញ៉ែមហ្នឹងនៅខាងកំពង់សោម ។ ដល់ចាប់តាញ៉ែមហ្នឹងទៅបាន គេដម្លើងតាវិទ្ធ នេះខាងនិរតី ។ ព្រោះតាញ៉ែមនោះកាលដើមនៅខាងខត្តរខ្សែជាមួយកុយ ធួនដល់គេចាប់ កុយ ធួន ចាប់តាញ៉ែម រួចទៅគេតំលើងតាវិទ្ធនេះ នៅខាងនិរតីជាប្រធានក្រសួងពាណិជ្ជកម្មទាំងក្នុងទាំងក្រៅប្រទេសទាំងអស់ ។ ដោយឡែកក្នុងប្រទេសបន្ទាប់ពីតាវិទ្ធ មកមានតាហុង ។ រៀបរាប់ទៅចូលគន្លងដូចប៉េង លាភ និយាយម៉ិចនេះណា ខ្ញុំរៀបរាប់ពីការចាប់ដល់ថ្ងៃល្ងាចចឹងទៅ បើត្រូវការចាប់អី ឡាននោះ ឡានដែលគេដាក់ថាឡានគេដាក់ថា "ម៨៧០"អីគេនោះឯង ។

ដារ៉ាៈ ម ៨៧០?

ហោៈ បាទ! ម៨៧០ សរសេរលេខតូច នៅផ្ទាកឡានអត់មានផ្ទាកអីគេ ហើយឃ្លុប ។ អាហ្ស៊ីបម៉ាស័រឃ្លុបវែង ។

ដារ៉ាៈ ហឺ! ឡានហ្នឹងអ្នកណាអ្នកគ្រប់គ្រងឡាន ម៨៧០?

ហោះៈ ខ្ញុំអត់ដឹង គ្រាន់បេះ ខ្ញុំដឹងគ្រាន់ថាថ្ងៃមួយខ្ញុំឃើញមកចាប់កន្លែងធ្វើការនេះ ។ កម្មករកំពុងធ្វើការ ខ្ញុំធ្វើការដោយឡែក ខាងម៉ាស៊ីនផ្នែកគទៅ ឈ្មោះមិត្តជា ៗ នោះជាប់ពាក់ព័ន្ធជានិរសាររបស់តាញ៉ែម ញ៉ែមដែលនៅកំពង់សោមនោះ ក៏គេចាប់មេនោះតាំងពីយូររួចហើយ តាំងពី៧៧រួចហើយ ដល់ចឹងគេស្រាវរកអាកូនដែលគ្នាអត់ដឹងអី និរសាពីជាន់នោះដល់នេះគេបំបែកមកនៅណោះ គ្នាមានដឹងអី គ្នាកំពុងតែលីសែង ដឹងថាប្រធានមន្ទីរនារីហ្នឹងទៅដល់គេត្រូចាប់អ្នកណា? អត់មាននិយាយពីការខុសត្រូវ គ្រាន់តែប្រធានមន្ទីរ តែម្ចាស់ខ្លួនអត់ដឹង ខំបកឈើ តាជា ៗ មកណោះ ។ គ្រលរអានិរតីឆ្កឆ្កា ។ មកម៉ាក្លែត ម៉េចបងមិត្តឯងមើលឈើនេះអាចធ្វើកាំភ្លើងបានទេ អានេះល្អកុហកគ្នាអានោះចេញក្លែតមក មកភ្លងកាំភ្លើងឡើងឡានចឹងបណ្ដោយ ។

ដារ៉ាៈ ឡានម៉ាកអី អាឡានមានផ្លាកហ្នឹង?

ហោះៈ ឡានអាហ្ស៊ីបម៉ាស័រនោះសម័យនោះមានតែអាស៊ីបូស័រក្តិតរាងវែងប៊ិនយ៉ុបរាងជិតយ៉ុបក្រណាត់ ចន្ទុលឡើងក្លែតបិតយ៉ុង ។

ដារ៉ាៈ ហឺ! កាលមក មកចាប់ហ្នឹងមានប្រាប់ឬប្រាប់ពីមូលហេតុអីទេ?

ហោះៈ អត់ទេ ឋានៈយើងនៅក្រោមអត់មានដឹងអីទេ ។ បើដឹង ៗ គេប្រាប់ត្រឹមប្រធានមន្ទីរឬថ្នាក់ប្រធានមន្ទីរ ។ បានថាខ្ញុំដឹងចឹង អាឡាននោះឯង ពីរថ្ងៃមុនចាប់តាជា ។ ថ្ងៃហ្នឹងមកលេងបែបសង្ស័យត្រឹមប្រធានក្រុមបេះតែឆ្ងល់ យូរប៉ះមួយ យូរប៉ះពីរ ឃើញឡានមក មិនដឹងគេមិនដឹងឯងបេះតែព្រួយហើយ ។ ទាំងគេទាំងខ្ញុំបុកពោះហើយដល់ឃើញចឹង មិនដឹងថ្ងៃណាទេ ថ្ងៃនេះគេហើយ ។ ថ្ងៃណាទេ អញភ័យ បេះតែភ័យបារម្ភព្រោះអីយើងអត់ដឹងប្រកត់ទៅពឹងអ្នកណាបាន ។ មិនដឹងរកកន្លែងណាត្រូវពឹងមានទិសដៅសំរាប់រត់រួនោះបានដឹងចុះ ដល់ឡានមកពិភាក្សាជាមួយប្រធានក្រសួង ហឺ!ទៅជាមួយប្រធានមន្ទីរ ដល់ស្អែកឡើងថាបាត់ខាងចំការមន អានោះសុទ្ធតែម៉ាក្រសួងនោះកន្លែងនោះ អានោះមានតាខ្មៅប្រាំងចំរេះ នៅទួលទំពូង ក្រសួងគេក្តាប់ឲ្យតែក្រសួងពាណិជ្ជកម្មក្រៅប្រទេសគេក្តាប់តែបាត់មិត្តនោះចាប់បាត់ ។

ដារ៉ាៈ ឡានដដែល?

ហោះៈ ឡានតែអាមួយហ្នឹង ដល់ស្អែកឡើងមុនចាប់អាជា ឡានហ្នឹងមកអង្គុយលេង ជាមួយគេអ្នកធំៗ ខ្ញុំមិនហ៊ានទេ ខ្ញុំនៅឆ្ងាយណាស់កៀកគ្នាចេះលេង ។

ដារ៉ាៈ ឡានពូមើលឃើញផ្លាកច្បាស់?

ហោះៈ បាទ! ឡានច្បាស់ ។

ឃិនៈ ឡាននោះមិនដែលទ្រុងទទេ?

ហោះៈ អត់ទេ ឲ្យតែមកឲ្យតែប្រធានមន្ទីរមន្ទីរបួញមាត់ហើយ គឺបាត់ហើយ ស្អែកឡើងដឹង តែបាត់ចឹងហ្នង ចេញមកវិញចាប់ ។

ឃិនៈ ចុះប្រធានមន្ទីរស្គាល់មនុស្សច្បាស់ម៉េស?

ហោះៈ ចុះប្រធានមន្ទីរគឺចង្កោម គឺថា៣០០ប្រធានមន្ទីរជាអ្នកគ្រប់គ្រងអាកន្លែងម្ដុំហ្នឹង ហើយប្រធានក្រសួងជាអ្នកបញ្ជាមក ។

ដារ៉ាៈ ចុះម៉េចដឹងឈ្មោះអីច្បាស់លាស់ម៉េស?

ហោះៈ ថី!ដឹងបើប្រវត្តិរូបនៅលើគេ គេគ្រប់គ្រងទាំងអស់ ។

ដារ៉ាៈ ហឺ! ឡានដែលមកចាប់ហ្នឹងផ្លាកធំឬតូចដាក់?

ហោះៈ ផ្លាកតូច ។

ដារ៉ាៈ ផ្លាកប៉ុនណាទៅ?

ហោះៈ ផ្លាកប្រហែលជាប៉ុនណេះ ។

ដារ៉ាៈ ចុះពូម៉េចបានជាបានពិនិត្យអាផ្លាកហ្នឹង?

ហោះៈ កាលដែលគេឈប់ចឹងទៅ ឈរជាមួយប្រធានមន្ទីរចឹងទៅ គឺថាដើរឆាក មើលឃើញចេះដូចថា ផ្លាកចេះ ផ្លាកស ។

ដារ៉ាៈ ពណ៌អីផ្លាកហ្នឹង?

ហោះៈ ពណ៌ដិតបិទ ពណ៌លឿង នេះដូចចេសឯង ដូចផ្លាកទង់ជាតិ បិទចេះ ប៉ុនគេដាក់៧៨០ ។

ដារ៉ាៈ ចុះអាផ្លាកហ្នឹងបិទនៅកន្លែងណា?

ហោះៈ បិទនៅមុខត្រង់មុខកញ្ចក់ប្រវែងនេះឯង ។

ឃិនៈ ពីរធ្លាប់?

ហោះៈ បាទ! អត់ដល់ខ្ញុំនេះដើរឆាកលេង ៗ ឆាកដូចថា គេអង្គុយចឹង ដើរហួសទៅ លបពីនេះទៅ អត់មានសំឡឹងមើលណាអត់ហ៊ានទេ ៗ

ដារ៉ាៈ ចឹងកាលហ្នឹងពូ ឃើញផ្លាក ម៨៧០ ពូយល់ថាម៉េចទៅ ជាឡានរបស់ណាពួកណា?

ហោះៈ មិនដឹងដែរ ៗ

ដារ៉ាៈ ចុះឡាន ម៨៧០ហ្នឹងធ្វើអី?

ហោះៈ មិនដឹងដឹង គេអត់ដែលប្រជុំប្រាប់ថាឡានហ្នឹងវាចេស ៗមួយ អត់ដឹង ៗ នៅធ្វើការជាមួយគ្នាដឹងតែតួនាទីរបស់ខ្លួនថា មុខសញ្ញាខ្ញុំត្រូវគ្រប់គ្រងម៉ាស៊ីន១០គ្រឿងនេះឯង កម្មករមានប៉ុន្មាន គឺអាស្រ័យនៅលើខ្ញុំជាអ្នកពិនិត្យ ៗ ម៉ាស៊ីនខូចខាតម៉េចមិត្តឯងត្រូវដោះស្រាយ បើថា បាក់ធ្មេញម៉ាស៊ីនអីមកទំនាក់ទំនងមកជាមួយប្រធានមន្ទីរគេ ៗ

ដារ៉ាៈ កាលហ្នឹងប្រធានមន្ទីរពូឈ្មោះអី?

ហោះៈ នារីម៉ិញហ្នឹង ៗ

ដារ៉ាៈ ឈ្មោះ ថាតហ្នឹង?

ហោះៈ បាទ! ហ្នឹងហើយ ៗ នៅនិរតីហ្នឹង ៗ ដល់ធ្វើការជាប់ ចុះបើទូទាំងប្រទេសទៅមើលផ្នែកយើង ទូទាំងប្រទេសគិតមើលមានតិចណា ៗ ក្នុងម៉ាឆ្នាំវៃអត់ហើយ សំរុកពេក ៗ ដឹកពីពាយ័ព្យសុទ្ធតែខ្សែរទេះភ្លើង ៗ ពីខត្តរឡាន ពីភូមិភាគបូព៌ាកប៉ាល់ទឹក មកទាំងខ្សែៗហ្នឹងហើយបញ្ចូលឃ្លាំងណែន ដូចថាវាអត់ទាន់ដល់រដូវផ្លែវា ថាយើងជិតអស់ហើយ នៅសល់តែម៉ាកូនឃ្លាំងតូចទេ ចឹងយើងធូរហើយ ម្នាក់ៗនាំគ្នាអរ ៗ ស្រាប់តែមិនទាន់នេះផង អាថ្មីមកដល់ពីប ៗណែនចេស ដូចដឹងស្រាប់ហើយវៃគវេទនាកម្ម ដល់ពេលបាក់ម៉ាស៊ីនចឹងទៅ ៗ ដល់ពេលម៉ាខែគេឲ្យសម្រាក៣ថ្ងៃ គេប្រជុំថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ ប្រជុំគេដើម្បីលើកមតិយោបល់ ៗ គេលើកថា យើងដឹងស្រាប់ហើយថា ខ្មាំងវាអត់ទាន់អស់ទេ អាខ្មាំងបង្កប់ ស្ពាបព្រាមួយបាក់ក៏នៅតែមានខ្មាំងបង្កប់ ៗ ខ្ញុំនឹកឃើញថាថ្ងៃណា ក៏គង់ខ្ញុំហើយ ៗ ព្រោះចាប់បន្ត យូរៗមួយ យូរៗបាត់បើមិនភ័យណា បើឯងចេះបាក់ទៅ ៗ

យិនៈ វាចេះតែបាក់អាម៉ាស៊ីនហ្នឹង?

ហោះៈ បាទ! ចុះបើដឹកសំឡីត មកវាច្រកបាវអាផ្នែកយើងហ្នឹង ដល់ច្រកបាវទៅ ដេរមាត់ មកពីគេនោះ ដល់ពេលនេះទៅ វាកាត់តែមាត់ទម្លាក់ទៅ ដួនកាលដែកប៊ិនណេះធ្លាក់ប្រាវបាក់

អាផ្អេញម៉ាស៊ីនហ្នឹងទៅ ។ មកទាក់ គេសរសេរសំបុត្រឲ្យទៅកន្លែងដ១ ដ២ ខាងកន្លែងក្រឡឹងឲ្យគេជូរារឲ្យចឹងទៅវាខាតពេលការងារ ។ ខ្ញុំយកមកចាប់វិញទៅខាតអាស៊ីនគេធ្វើ ។ សំឡីគហ្នឹង យកមកម៉ាស៊ីនវាវៃ ដូចត្បាល់បកនេះឯង អាចាប់ម៉ូទ័រអា១០ទៅ១២ សេសឲ្យវាក្រអូម ។ ភ្លើងនោះដុំបំបែកវៃងណាស់តាំងពីនេះទៅដល់ដើមស្មាយខ្ញុំ ។ បើសិនណា គេកើបមុនដំបូង គេហៅសំឡីលេខ១ អាសមកច្រកបាវចឹងទៅអា កណ្តាលលេខ២ អាលេខ៣ ទុកវាមួយកណ្តុប ហី! អាគ្របវានោះវាត្រង់មក វាយកធ្វើសាប៊ូ ។ យកធ្វើសាប៊ូទៀតគ្មានចោលទេ ហើយអាសំបកនោះឡានជញ្ជូនដឹកយកទៅចោល ។ អាផ្នែកដឹកសំបកចេះតែដឹកទៅទាំងយប់ទាំងថ្ងៃ ។

ដារ៉ា: ក្នុងនោះមានប៉ុន្មាននាក់ទៅ?

ហោះ: ក្នុងម៉ាស៊ីនម៉ាគ្រឿងកម្លាំង១០នាក់ ៧នាក់ ។ ហី!១០គ្រឿង ។ ខ្ញុំថា! អូអត់រស់ទេ ។

ដារ៉ា: ចឹង ពូមើលទាំង១០គ្រឿងហ្នឹង?

ហោះ: បាទ! មើលទាំង១០គ្រឿង ថ្ងៃណាខ្ញុំអត់រួចខ្លួនទេ ។ ហើយប្រធានពីលើខ្ញុំ ក្នុងកងហ្នឹងដែរ ក៏នៅនេះដែរ ខាងនិរតីដែរ ។

ដារ៉ា: ឈ្មោះអី?

ហោះ: ឈ្មោះមិត្ត អាយុនោះមិនដាបើទេ ភ្លេចទាំងឈ្មោះហើយ ។ អូ ឈ្មោះមិត្តអឿន ខាងនិរតីដែរ សុទ្ធតែពួកនិរតីហើយ យើងនេះឲ្យនៅក្រោម ប៉ុនថាធ្វើនេះដែរ ប៉ុននៅក្រោមការគ្រប់គ្រងរបស់គេទាំងអស់ ។ ដល់ចេះទៅខ្ញុំឈឺខ្ញុំដរមុខរបួសនេះ ។ សុំទៅសម្រាកពេទ្យដល់ទៅសម្រាកពេទ្យចឹងទៅដល់ពេលត្រឡប់មកវិញ ។ អានោះថ្ងៃអន្ទរខ្ញុំ ចូលដល់ហើយ ។ ក៏ខ្ញុំនឹកគ្នាឯង នឹកមិត្ត រី បើនៅនោះ នៅស្រុកកំណើតឈ្មោះមិត្តខាន់ ។ បើនៅណោះ មិត្តរីនេះឯង មិត្តខាន់ គាត់ស្រឡាញ់ណាស់ ។ ខាងសំរិតសំរាំងគាត់ស្រឡាញ់ គាត់ទុកចិត្តនេះអាចឹងពីការងារលាក់ការណ៍ផ្ទៃក្នុងរបស់គេ ។

ដារ៉ា: ឈ្មោះមិត្តរី?

ហោះ: បាទ! មិត្តរី ។

ដារ៉ា: នៅរស់?

ហោះ  នៅរស់ នៅភូមិជាមួយខ្ញុំ ឈ្មោះមិត្តខាន់ ដល់ខ្ញុំចេញពីពេទ្យចឹងមកយប់ឡើងខ្ញុំដើរ ទៅលេងរលឹកគ្នាឯង ។ ខ្ញុំទៅដេកពេទ្យយូរគ្រាន់ហើយ ខ្ញុំទើបដើរទៅលេង ។

**sideB**

ហោះ  ធ្វើម៉េចដោះស្រាយកើតបើជាប់ចឹង រកច្រកវាមិនឃើញ មានតែផ្លូវមួយព្រោះប្រធានមន្ទីរគេថា គេចោទថាឯងនេះ ប្រើកម្មករអត់មានពេលសម្រាកកម្មករគេប្ដឹង ដល់ប្រធានក្រសួងប្ដឹងដល់តារិទ្ធនោះ ប្រធានក្រសួងពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ប្រធានធំជាងគេ ប្ដឹងថាហ្អែងប្រើកម្មករអត់មានពេលសម្រាកទេ ។ ពេលដូចថាម៉ោង១០ កន្លះត្រូវឈប់ផ្ដួតទឹកម៉ោង១១ត្រូវហូបបាយចឹងទៅចេញពីបាយនេះ ថាខ្ញុំនេះថ្នៃការ នេះឯងឲ្យកម្មករនេះអត់បានពេលសម្រាកទេ ម៉ោង១ចូលឯងថ្ងៃកន្លះម៉ោងឲ្យបោសសំ អាគតាមកន្លែងរស់នោះណាគេណោះ ។ ខ្ញុំធ្លាក់ថ្លើមក្ដុក ថាជួយគិតអញមើល គិតម៉េច ពេលចឹងមានតែផ្លូវផាប់ហើយ ព្រោះយើងមានកន្លែងណារត់ទៅណារួច អត់មានក្រឡារត់ ទេរត់មកស្រុកមិនដឹងជារត់មកម៉េច រត់ទៅសហករណ៍សុទ្ធតែគេ ។

ដារ៉ាៈ  ចឹង ឈ្មោះរីដែលប្រាប់ពូស្រីឬប្រុស?

ហោះ  ប្រុស ។

ដារ៉ាៈ  រីហ្នឹង?

ហោះ  បាទ! ចេញពីភូមិកំណើតជាមួយតែគ្នាហ្នឹងទាំងអស់ ។

ដារ៉ាៈ  ហឺ! ឥឡូវឈ្មោះអី?

ហោះ  ខាន់ នៅឈ្មោះកំណើតឈ្មោះខាន់ ដូចខ្ញុំឈ្មោះហោចឹង ។

ដារ៉ាៈ  នៅរស់?

ហោះ  នៅរស់ ។

ដារ៉ាៈ  នៅណា?

ហោះ  នៅនេះ នៅនេះ ។

ដារ៉ាៈ  នៅក្បែរនេះទេ?

ហោះ  បាទ! នៅនេះទេ ។

ដារ៉ាៈ  ហឺ! ជាអ្នកទុកចិត្តរបស់រិទ្ធហ្នឹង?

ហោះ៖ បាទ!រិទ្ធ ហ្នឹងស្រឡាញ់វា ស្រឡាញ់វា អាចខ្សឹបប្រាប់វាឈ្មោះនេះឈ្មោះនោះ អាចចុច ខ្ញុំអាចដឹង វាប្រាប់ខ្ញុំ ។ វាថា ចេះទៅបងថាត ឯងសាប់ក៏សាប់ទៅបិុនបើមុននឹងសាប់ហ្អែង ចូលទៅជួបជាមួយប្រធានមន្ទីរប្រាប់គាត់ត្រង់ ពីរឿងហេតុថាមូលហេតុដែលធ្វើចេះឯង នេះ មិនមែនយើងជាអ្នកកំណត់ខ្លួនយើងទេ គឺបទបញ្ជាដែលពីលើមក យើងត្រូវគោរពគេ តាមថ្នាក់ហ្នឹង ។ ទៅជួបគេផ្ទាល់ បើថាសាប់ក៏សាប់បើថារស់ក៏សំណាងយើងល្អ ។ ខ្ញុំទៅជួប ប្រធានមន្ទីរដែលថានារីហ្នឹង ។

ដារ៉ា៖ ឈ្មោះ ថាតដែរ?

ហោះ៖ បាទ! ហ្នឹងដល់ពេលយប់ម៉ោង១០ គេរៀបបិទទ្វារកន្លែងបន្ទប់គេដេកហើយរុញទ្វារ ហើយខ្ញុំទៅដល់ពីប យប់ចុះភ្លើងភ្នំពេញនៅតែភ្លឺទាំងយប់ទាំងថ្ងៃ ។ ខ្ញុំទៅដល់គាត់អត់ដឹង ថាខ្ញុំចេញពីពេទ្យទេ ។ ខ្ញុំសំណេះសំណាលដឹងរឿងវីងមកមកចឹង ដូចថាវត្តចេសប្រធាន មន្ទីរគេនៅត្រង់ណោះ ខាងកើតវត្តទួលទំពូង ។ ខ្ញុំឈរស្រាប់ថាមិត្តឯងចេញពីពេទ្យហើយ ដែលថាឈ្មោះមិត្តថាតនោះ ។ ខ្ញុំថាបាទ! គាត់ចាត់តាំងស្គាល់ខ្ញុំច្បាស់ដែរ ។ ខ្ញុំសួរដែរ ខ្ញុំថា បាទ! ចុះចេញពីពេទ្យយូរហើយ ខ្ញុំថាទើបមកដល់ មកដល់អាស្មើម៉ោង៩កន្លះហ្នឹង ។ ចឹង មកមានការអី ខ្ញុំនិយាយថាហ្នឹងហើយសំលេងគេចុះនិរតី ។ ក៏បើកទ្វាដាក់កៅអីឲ្យខ្ញុំ អង្គុយ ខ្ញុំនិយាយប្រាប់ហេតុច្បាស់ ថាបងទោះគេប្អូនក៏ហៅគេបងដែរ ព្រោះឋានៈ ខ្ញុំចង់ ជួបនឹងបងផ្ទាល់ថា និយាយពីបញ្ហាខ្លួនខ្ញុំផ្ទាល់ហ្នឹងឯង ។ រឿងខ្ញុំទាំងឡាយណាដែលកន្លង មកហ្នឹងឯង ខ្ញុំថា ខ្ញុំមិនមែនធ្វើដោយគំនិតខ្លួនឯងទេ ខ្ញុំគោរពតាមវិន័យអង្គការចាត់តាំង របស់បក្សខាងលើ ខ្ញុំមិនមានគោលការណ៍ទៅថា ចេះច្នៃប្រឌិតការងារដើម្បីលើកមុខលើក មាត់ឲ្យមានតួនាទីដីណែងចង់បានធំចង់បានតូចប្តូមួយណានោះទេ ចឹងខ្ញុំគោរពអង្គការវិន័យ ខ្ញុំមិនដឹង វែកងតែថ្នាក់លើដាក់ចឹងឯង បទបញ្ជាចឹងឯងក៏ខ្ញុំធ្វើទៅតាមនោះមែន ។ មិន មែន ខ្ញុំធ្វើតាមគោលបំណងដោយខ្លួនឯងនោះទេ ។ ខ្ញុំនិយាយប្រាប់ហេតុផលស្រួលបួល ទៅ ថាមិនអីទេទោសម្រាកទៅ ចុះម៉េចបានវះអត់អំបែង ខ្ញុំថាអត់ទេបង ព្រោះអាហ្នឹង ទាល់តែទៅពេទ្យ គេបញ្ជូនទៅពេទ្យ១៧បានសម្រេចវះបាន ព្រោះអំបែងខ្ញុំកប់វាកប់ជ្រៅ គេឆ្លុះទៅ ខ្ញុំថាមិនកើតទេ ។ ខ្ញុំសុំចេញមកវិញចុះ ពេលណាបើអំបែងហ្នឹងវាធ្វើទុកក៏ខ្ញុំសុំ

សម្រាកនឹងពេទ្យក្រសួងចុះកុំឲ្យពិបាកទៅ ពេលណាវាអត់ធ្វើទុកទេ ខ្ញុំជួយធ្វើការ ។ អាំស ទៅសម្រាកចុះ ។ បានតែមាំរំលងលក់មាំយប់ទេ ស្អែកឡើងចាប់បាត់ ។

ដារ៉ា: ចាប់ពីណាគេ?

ហោះ: ចាប់មីប្រធានដែលពីលើខ្ញុំខាងនិរតីគ្នាគេដែរចាប់ភ្លែតព្រោះគេជាប្រធានខ្ញុំបន្ទប់អនុប្រធាន កងធំ ។

ឃិនៈ ឈ្មោះអី?

ហោះ: ឈ្មោះ អឿន ។ ចាប់ភ្លែតដកទៅថ្ងៃ១០គេទៅប្រជុំ ។ ១០គេប្រជុំដូចថាសប្តាហ៍គេដាក់ មាំខែ៣ថ្ងៃ ។ ៣ថ្ងៃឲ្យកម្មករសម្រាកប្រជុំនិយាយពីការងារ ប្រធានក្រសួងគេចូលរួមប្រជុំ ស្តាប់របាយការណ៍ឆ្លើយតបនឹងការងារនោះវាបានយាំងម៉េចៗខ្លះ ទៅចឹងទៅគេលើកភ្លែត ថា នៅមានជនបង្កប់មិនចេះអត់មិនចេះចប់ ។ ខ្ញុំថានឹកឃើញ បើកកុំបានអាគ្នាឯងលួច ឱ្យបប្រាប់ កុំអីកុន ហី! គ្នាគេសុទ្ធតែនិរតីគ្នាគេជងនៅតែចាប់ខ្លួន ។ ចុះបើសិនជាអត់មាន អ្នកណាឱ្យបប្រាប់ខ្ញុំ ត្រូវតែងាប់ ។ អាហ្នឹងថា វាសនាខ្ញុំមិនត្រូវទៅរួច ខ្ញុំនិយាយត្រង់ ។ នេះបើសិនជាមានកន្លែងរត់ដូចយើងឥឡូវ អូរត់បាត់តាំងពីពីជំនាន់ប្រាំងចំរេះបាត់ហើយ ប៉ុនមិនដឹងរត់ទៅណារួច ។ បានវាប្រាប់ថាហ្អែងទៅជួបទៅ វាម៉េចក៏ម៉េចទៅ ។ ខ្ញុំទៅត្រង់ មែន ត្រង់វាប្រាប់ចឹង រំលងបានតែមាំថ្ងៃហ្នឹងភ្លែតចាប់បាត់ ។

ឃិនៈ កាលពេលហ្នឹង?

ហោះ: ចាប់បាត់ ។

ឃិនៈ ចាប់ប្រធានពួងហ្នឹង?

ហោះ: បាទ! ចាប់យកទៅបាត់ ។

ដារ៉ា: ឡានម៉េចមកចាប់ ឡានអីទៀតទេមកចាប់?

ហោះ: ដែលចេស កាលហ្នឹងកំពុងចាប់ ខ្ញុំអត់ដឹង មានតែឡានហ្នឹងឯង ដូបតែឡានហ្នឹង មួយអត់ មានឡានអីចំឡែក ។ ពីអាឡានហ្នឹងទេ ។ ឲ្យតែមកគឺបាត់មនុស្សៗ ។

ឃិនៈ ចាប់ ចាប់មកពីមេហ្នឹងដែលអនុគ្រោះឲ្យពួហ្នឹង?

ហោះ: មកពីប្រធានមន្ទីរហ្នឹងគិតទៅ គេអ្នកឲ្យពត៌មាន ថាខ្ញុំនេះមិនមែនជាអ្នកធ្វើខុសទេ មានពី លើទេ មានបទបញ្ជាឲ្យខ្ញុំធ្វើនោះ ។ ចឹង គេចាប់ពីលើខ្ញុំ ។

ដារ៉ាៈ ចាប់ពីលើទៅប៉ះអឿនហ្នឹង?

ហោៈ បាទ! ប៉ះអឿនហ្នឹងទៅខាងនិរតីគ្នាគេ ត្រង់អាស្លាប់ត្រង់រស់ម៉េចខ្ញុំអត់ដឹងទេ។ បើចាប់ៗផុតទៅបាត់ពេលហ្នឹងមក។ បានក្រោយបន្តបន្ទាប់មកទៀតទៅ បានប៉ុន្មានវិលមក ចេញពីពេទ្យហ្នឹងទៅវៀតណាមជិតចូលហើយ។ ក៏ដល់ធ្វើការបានម៉ាខែ ព្រួសស្ទួរផ្ទុះអាវុធ ថាម៉េចចេះ។ ភ្លើងមកទៀតហើយ ដល់ថ្ងៃ៥ គេជម្លៀសបរទេសទៅក្រៅ។ ថ្ងៃ៥ខ្ញុំមកប្រជុំ។

ដារ៉ាៈ ឆ្នាំណាថ្ងៃ៥?

ហោៈ ថ្ងៃ៥ ឆ្នាំ៧៩។

ឃិនៈ បែក ៧មករាហ្នឹង?

ហោៈ ហ្នឹងហើយ ថ្ងៃ៧ហ្នឹងឯង។ កំណត់ថាថ្ងៃ៧មករានោះឯង បើថាថ្ងៃ៥នោះឯងមិនត្រូវ។ ថ្ងៃ៧ត្រូវកំណើតយើង។ ដល់ថ្ងៃ៥នឹងគេត្រូវជម្លៀសបរទេសទៅក្រៅដឹកពីណាទៅណាពីកំពង់ចាមអីទៅ ដូចទូកអីចេញទៅកំពង់សោម។ ហី! ខ្ញុំបានប្រជុំព្រឹកមក ប្រជុំគេនៅបុរីកីឡានេះឯង។ ប្រជុំហ្នឹងខៀវសំផន ខ្ញុំបានឃើញគាត់ផ្ទាល់នោះឯង។ គាត់និយាយចឹង ខ្ញុំដឹងភ្ញាក់ខ្លួន។

ដារ៉ាៈ និយាយថាម៉េច ខៀវ សំផន?

ហោៈ គាត់និយាយថាចេះ ថា បងប្អូននិយាយហ្នឹងនិយាយអស់សង្ឃឹម និយាយទល់ព្រួ។ ខ្ញុំថានិយាយអីចេសថាក់ដឹកនាំប្រទេសមួយមកនិយាយចឹង។ ហី! ប៉ុល ពត ហ្នឹងទៅបាត់ហើយ អត់នៅទេ។ ទៅយូរហើយ តាំងពីដឹងខ្លួនគេរត់ចេញក្រៅបាត់ទៅហើយពួកនោះ។ ទៅទុកឲ្យខៀវ សំផន នៅក្នុងប្រទេស។ ខៀវសំផននៅទាល់តែវៀតណាមចូលបានរត់។ គាត់និយាយថាទោះបីអាវុធឬយន្តហោះទម្លាក់គ្រាប់បែកនៅម្តុំអរិយក្សត្រយ៉ាងណាក៏ដោយ។ ចេះយើងជាប្រធានក្រុមប្រធានកងតូច ប្រធានអនុសេនាធំទាំងអស់ត្រូវដឹកលេណដ្ឋានពង្រឹងសារដើមវិញ មិនអាចរត់ចេញពីកន្លែងទីតាំងរបស់យើងជាដាច់ខាតកុំបាក់ស្មារតី។ និយាយចឹងនិយាយយ៉ាងម៉េចចេះ ដូចឆ្ងល់ដល់ហើយ។

ដារ៉ាៈ ប្រជុំគ្នាច្រើនទេ?

ហោៈ អូ! និយាយវែងណាស់មិនអាចចាំបានទេ។

ដារ៉ាៈ តែគ្នាច្រើនទេ?

ហោះ៖ អូ ប្រជុំនោះគ្នាច្រើន សុទ្ធតែមេ ។

ដារ៉ា៖ នៅស្ពាត?

ហោះ៖ បាទ! នៅស្ពាតសុទ្ធតែមេៗកងប្ញវរសេនាតូចអីបានគេហៅ មហាជនធម្មតាអត់ទៅ អស់ទេ ត្រឹមកងធំឡើងលើ ។ ក៏ប្រជុំគ្នាទៅប្រាប់គ្នាវិញ ។ ចេញពីប្រជុំវិញមកវិញ ប្រជុំនៅក្នុងក្រសួងប្រធានក្រសួងរៀបចំដឹកត្រង់សេដឹកអី គិតមើលឡានដឹកបរទេសស្ពានណោះ ដឹកដាប់ទូតចិនអីណាត្រូវចេញ ។ ទាហាន អូបានដឹងថាចេញទាហានដែលនៅការពារបរទេស គឺសិទ្ធតែឡានទេសចរណ៍សុទ្ធតែជិះឡានហើយកាន់អាវុធអមទាំងអស់ ។ អូ! បែបសភាពការអត់ស្រួលទេ ចេះតែខ្សឹបគ្នាឯងចឹងមើលទៅម៉េចចេះ ។ ហឺ! កាំភ្លើងកាន់សុទ្ធតែអ្នក នោះ កាំភ្លើងនោះ ។ ពូសូវ្យគ្រាំងៗពូសូវ្យឯងបុកពោះគ្រឹបៗ យ៉ាងណាយ៉ាងណី ។ ស្រាប់ដល់រំលងម៉ោថ្ងៃថ្ងៃ៦ ថ្ងៃល្ងាចថ្ងៃ៦ នោះឯងធ្វើការចេះទៅក៏ដូចវាអត់មានកម្លាំង ។ វាដូចរាងរសាយចិត្ត អត់ខ្លាំងដូចមុនក៏ខ្ញុំសម្រាក ម៉ោង៩ចូលសម្រាក អាយប់ថ្ងៃ៦ ៦មករា យើងឆ្នាំ៧៩ នេះ ។ ចូលសម្រាកចឹងក៏មានឈ្មោះមិត្តអេនៗនៅកំពង់ចាម ។ វាជិនិតជាមួយខ្ញុំដែរ វានៅក្នុងក្រុមខ្ញុំផង ។ នៅក្នុងកងហើយនៅក្នុងក្រុមជាមួយ ជាមួយទៀត ។ ខ្ញុំចូលសម្រាករកបិទភ្លើងវាកោះទ្វាប៉ូក ។ បងជាត ខ្ញុំថាម៉េច បើកទ្វា ដេកអីទាំងក្បាលល្ងាច ។ ខ្ញុំចេញ ហ្អែងហៅលេងឬហៅមែនបើកទ្វា គេរត់អស់អាលឹង ។ ចឹង អានេះនិយាយលេងឬនិយាយមែន អានោះវាធ្លាប់កំប្លែង ។ ក៏បើកបង ហ្អែងគេយកប្រពន្ធខ្ញុំទៅអស់អាលឹងហើយទៅប្រជុំនៅកន្លែងក្រសួង ។ ហឺ! ស្រីៗកំពុងធ្វើត្រីធ្វើដោយដៃ ព្រោះត្រីអាខែ១ វាត្រូវគេចែកដឹកទាំងឡានខ្ញុំកំពុងធ្វើមានទាន់បានហូបបាយណា ស្រីៗនារីនោះ ។ ហឺ! ប្រពន្ធវាទើបរៀបការថ្មីដែរ ។ ប្រពន្ធវានៅសៀមរាប ហឺ! ខ្ញុំអត់ទាន់មានប្រពន្ធមានអីទេ កាលហ្នុងនោះ ។ ដល់ខ្ញុំមកមកកន្លែងក្រសួងបន្ទាប់ពីនារី នោះឯងមានមិត្តធនៗហ្នឹងឯង គេស្នងឲ្យខាងក្រសួងតារិទ្ធគេអ្នកចាត់តាំងព្រោះគេទុកចិត្តអាគាត់ហ្នឹង ។ គេចាត់តាំងថា ឥឡូវមិត្តឯងរៀបចំកម្លាំងលីនផ្ទុំលដាក់ឡាន ។ អាឡានយើងធំពីមុននោះ ភ្លែចឈ្មោះឡានហើយឡានយើងទ្រុងៗពីដើមនោះ ។ អាសែងសង់សីសង់ ។ លីឲ្យពេញ៨ឡានហើយប្រកាសប្រាប់ថា កុមារៗឲ្យឡើងឡានទាំងអស់និងនារីៗ ទុកតែកម្លាំងបុរសគឺនៅតាមកន្លែង តាមក្រុមតាមកងរៀងៗខ្លួន ។ ខ្ញុំថាអីយ៉ាសភាពការណ៍អត់ស្រួលទេ នារីៗយំ

ក្រេវទ្រហឹង ចុះបែកប្តីបែកប្រពន្ធគេឲ្យយួរវ៉ាឡ្លូ ។ សម្លបាយអីនៅទាំងខ្ទះៗដែលខទុក ព្រឹក ។ ខ្ញុំថាដល់ហើយនេះ ចាប់ផ្ដើមភ័យហ្មង អូ!យើង ម៉េចចេះនេះ ។ ទៅណាមកណី បើគេយកកុមារអស់នារីអស់នៅហ្អែងបុរសៗពីទឹកខ្មៅ មកប្រមូលគ្នាមកទួលទំពូងទាំងអស់ បុរសៗ ។ ក៏ម៉ាយប់នោះឯង អត់បានសម្រាក ។ ជិនុំគ្នាហ្មងកាំភ្លើងកាន់តែមកហ្មង កិតឡើងៗពីដើមឮឆ្ងាយដល់យូរទៅកាន់តែជិតឡើង យី!ម៉េចចេស ។ កុមារអាពតគេមក ចាត់តាំង គេថាឥឡូវព្រឹកនេះម៉ោង៨ អ្នកមានអាវុធគឺត្រូវត្រៀមកាត់ច្រកនេះឯង ។ ឲ្យកាត់ច្រកនេះឯង បើវាចេញមក ចេញតាមណា បើស្ពានមុន្នីវង្ស បើផ្លូវក្បាលថ្នល់ នោះឯងបានកាត់មកវិថីសេរីភាពបានកាត់មកតាមផ្លូវនោះឯងមក បុកស្ទឹងមានជ័យនោះ ឯងព្រោះបុស្ដិ៍វិទ្យុ ។ អីយា!ផ្ទើនេះមែនទែនហើយ មិនដឹងទៅណាទៅណី ។ បងហ្អែងមាន ជ្រូកទន្សាយកៅស៊ូចិញ្ចឹមទាំងទន្សាយម៉ាកងៗ ទន្សាយ ក្នុងកងធំខ្ញុំជិត១០០ទន្សាយអត់ ហ៊ានស៊ីទេ ។ គិតតែខ្លាចគេ ខ្លាចគេក្រែងគេវៃ យួនមកវិញ ។ ចាប់យើងទៅវៃចោល នែកុំស៊ីខាតចឹងទៀតអត់ហ៊ានស៊ីមាន់ក៏មិនហ៊ានអាជ្រូកតាមកងផ្សេង អាតាមក្រសួងរាប់ រយក្បាល ។តាមក្រសួងបើថាចិញ្ចឹមតាមកង បានត្រឹមពី៦០គីឡូឡើងយកទៅដាក់កន្លែង ក្រសួង ។ កន្លែងក្រសួងចិញ្ចឹមមានទៅដល់២០០ឬ១៨០គីឡូ ។ ខ្ញុំថាដល់កហើយនិយាយ ពីជ្រូកពេញវាលហើយម៉ូតូអាកន្លែងអាមន្ទីរហ្នឹងឯង ខ្ញុំកាលណោះដូចជាល្ងង់អត់ចេះយក ឥវែតវ៉ាន់ បើគំនិតវែងដូងយើងនេះ រត់មកចេះមករួចបាត់ ។ ភ័យហេតុតែភ័យហួស ម៉ូតូអត់ជិះគិតតែរត់ដើរទទេហ្មង ។ រត់ព្រាងឡើងមនុស្សមក មនុស្សមករត់វ៉ាស់ព្រឹក យប់នោះ ។ភ័យហ្មង ។ ម៉េចចេះមនុស្ស ចេះតែមកពីកើតមកពូនមក ។ ទាំងកុមារទាំងនារី ហើយអាឡានឯងទៅបាត់ហើយ៨គ្រឿង ។ដឹកស្រីៗនិងកុមារៗទៅបាត់អស់ហើយ ថាទៅ បើយ៉ាងណាគេឲ្យទៅជួបគ្នានៅបរិលខេត្តបាត់ដំបងកន្លែងក្រសួងគេទៅចាំនៅណោះ ។ អូ ម៉េចចេស ស្រាប់ព្រាងឡើងម៉ូតូ ហី! យើងអត់មានម៉ូតូឥឡូវទេ មានតែសេអ៊ិលអីទេ ។ មានមេទាហានមួយអត់ស្គាល់ទេ ជិះម៉ូតូមកថាពូមិត្តកុំរត់ បើមានអាវុធ ចាំស្ទាក់តាមផ្ទះថ្ម ហើយបើរត់ក្រោះ ចេញមកគឺបាញ់បុកហ្មង ។ អូ ដល់ហើយ ម៉េសយើងដល់ពេលហើយ គស់អាណាម៉េចៗទៅគ្មាន មេគ្មានកូនទេរត់ចូលគ្នាហ្មង គ្មានជីដូនជីតាណាទៅបាត់ទៀតទេ វើយ ។ មិនមែនម៉ែអញទេ ពូនហ្មងរត់យកហ្មង ។ គេដោយគេខ្ញុំដោយខ្ញុំរត់ទៅ

និយាយពីក្រណាត់ស្តីឱ្យ និយាយណាស់ ។ បើដឹងពីគំនិត បើដឹងចឹង មាសពេជ្រអី វាដាក់នៅមន្ទីរអី ហ៊ីតវ៉ាន់អីៗ ទាំងអស់ម៉ូតូថ្មីៗច្រើនៗ អត់ទេ ។ រត់យកមាឈ្មោះដៃ ។ រត់យកតែខ្លួន ខ្ញុំរត់ចូលមកស៊ឹងមានជ័យ ។ ហើយបានកាត់មកអូរបែកក្អមមកចេស ខាងណោះពោចិនតុង ។ ចេញដល់អូបែកក្អម វៀតណាមប្រហែលជាដល់កណ្តាលភ្នំពេញ ខ្ទុះពីង ឃើញផ្សែងហុយទៅលើ ថាដល់ហើយ ដល់ហើយយើងទៅត្រង់ណា ទៅណាទេ ។ ទេ កាលពីនៅក្នុងវាខ្លាច ដល់វាលស្សុទ្ធតែសាច់មនុស្សអូ! បើគេឯាប់ ក៏យើងឯាប់ដែរឱ្យ ។ វាណែន ណែនបែសដល់ពោធិចិនតុង ។ សុទ្ធមនុស្សរុញកុមារ ។

ដារ៉ា៖ មនុស្សហ្នឹងជាមនុស្ស?

ហោះ៖ មនុស្សរត់ចេញ ។

ដារ៉ា៖ ជាខ្មែរក្រហម ឬជាប្រជាជន?

ហោះ៖ ជាខ្មែរក្រហមនៅតាមទីក្រុងដូចទ័ពទៅកម្មករទៅវាច្របូលច្របល់អស់ហើយនោះ វាចេញពីទីក្រុងមក ។ វិលនោះឯង ខាងវិទ្យុជាតិ វាពោរពាសណែនណាំតាន់តាប់រត់ ។

ឃិន៖ ចឹងច្រើនណាស់ ។

ហោះ៖ បានវាថា ដែលព្សូរនោះថាផ្ទះនៅពោធិចិនតុងនោះខ្ញុំនិយាយការពិត គឺផ្ទុះចំកណ្តាលផ្សារថ្មី ។

ដារ៉ា៖ ផ្ទុះកន្លែងផ្សារថ្មី?

ហោះ៖ បាទ! បាញ់បុកកន្លែងនោះវាចង្កោម ។ ដល់ខ្ញុំទៅដល់ពោធិចិនតុងបានដឹងថា ខៀវ សំផន គេរត់ចេញ ។ យកឡានគាត់មួយជាមួយនឹងហ៊ូ នឹម គាត់រត់ចេញមក ។

ដារ៉ា៖ ចុះហ៊ូ នឹម នៅដល់?

ហោះ៖ អត់ទេ ខុសទេ ខៀវ សំផន គាត់នៅម្នាក់ជាមួយ តា យ៉ុន ខាងចំរៀងអាយ៉ៃពីសង្គម គាត់នៅជាប់ជាមួយនោះឯង ។ គាត់នៅជាប់នោះឯង និងនិរសាគាត់មួយ ។ មានរថក្រោះ៤គ្រឿងអបគាត់ ។ រថក្រោះអត់មានតទេ រត់ទៅហ្នឹង ។

ឃិន៖ បើកអបឡាន?

ហោះ៖ បាទ! បើកអបឡាន គាត់យ៉កហ្នឹង ជាមួយ...? និងនិរសាមួយជាប់នៅខាងណោះ ។

រត់មានរត់ ទៅហ្នឹងទេ ព្រោះប៉ុល ពត អីទៅអស់ នៅតែខៀវសំផនមួយ ក្រោយពីផ្ទុះអាវុធបានរត់ចេញ ។ ក៏ខ្ញុំដំណាលចេស ចេះតែពូនចេះតែទៅៗ ទៅដល់ហួសចោមចៅចឹងទៅឃើញឡានមួយ ។

យិនៈ ចឹង យ៉ុនហ្នឹងទើបរត់ទៅក្រោយ?

ហោះ រត់ក្រោយ ។

យិនៈ ជាខ្មែរក្រហម ឬជាប្រជាជន?

ហោះ អត់ទេនៅទេ អត់មានសម្លាប់ទេ ។

យិនៈ ពូថាដើរតាមខៀវសំផនជាប់?

ហោះ ជាប់ បានខ្ញុំដឹងចេស និយាយរៀបរាប់ប្រវត្តិនៅភ្នំពេញចេស គាត់ច្រៀងចាប៉ីនាយអាយអីទេ ។ គាត់អ្នកចំរៀងដើងចាស់ ។ ដល់ខ្ញុំទៅចេសទៅក្នុងក្រសួងខ្ញុំឈ្មោះតាខែមៗ គាត់បាត់កូនអស់អាលីងហើយ គាត់គាកុងឡានពីសង្គម ។ ចំណាស់ដូចបងឯងចេស គាត់ថាយីឡាននេះមានម្ចាស់អត់ពូមិត្ត មិនដឹងទេ អត់មានសោមានអី យីធ្វើខ្មែរក្រហមយូរណាស់ហ្អែង នាំគ្នារុញអញធ្វើតែកុង អើបើគាឯងចេះបើកឡើងទៅ មិនដឹងឡានអ្នកណាឡានអ្នកណី ឡានរដ្ឋតើ ។ គាត់ក៏ឡើងទៅភ្លែត គាត់ថា ហ៎ករុញ ក៏នាំគ្នារុញឆេះវូអ្នកណាឡើងទាន់ក៏ឡើងអ្នកណាឡើងមិនទាន់ក៏អត់ ។

យិនៈ បើករត់?

ហោះ បាទ បើកឡានទៅ ខ្ញុំឡើង ឡើងបានគ្នាក្រើលដែរម៉ាឡាននោះ ។ អាអ្នកឡើងមិនទាន់ក៏រត់ទៅពូន ដល់រត់ចឹងទៅ ទៅដល់ថ្នល់ទទឹង ។ ដល់ថ្នល់ទទឹងចេស ស្រាប់មានឡានម៉ាខ្សែមកពីកំពង់សោមបញ្ច្រាសមកវិញ ។ ចុះម៉េច ថាយួនបុកចូលណោះ ។ ចុះយួនអីក៏ច្រើនម៉េសចឹងទៅណា ។ មកពីនោះហើយ ថាទៅណា ទេមិនកើតទេ គេថាទៅផ្លូវនេះ ។ ទៅអាផ្លូវលំនេះបាន បាន ទៅផ្លូវលំនេះឡើងទៅត្នោតពង ។ មិនដឹងណាណីទេ ចេះតែបរតាមគេហើយគាត់ ។ ដល់បរៗធ្លាក់មកផ្លូវលំម្តុំកំពង់លួង មានផ្លូវលំមួយគ្រួសក្រហម ដល់បរមកផុតពីគ្រួសក្រហម ដល់អាដីខ្សាច់ ។ ដល់ដីខ្សាច់ យប់ហើយឡានគេមានឌីមារ័រអីត្រឹមត្រូវភ្លើងអីគេចេះទៅ មានអីឡានឯងជាប់ខ្សាច់លេងរលត់រុញណារុញរួចបើសុទ្ធតែខ្សាច់ក៏ចោលនាំគ្នារត់ជើងទទេ ឡាននោះក៏ចោល ។ រត់ទៅបានប្រធានភូមិភាគនិរតីនេះ ។

យិនៈ តាម៉ុក?

ហោះ តាម៉ុក គេឲ្យកាត់ពីអមលាំងមក ខ្ញុំទើបឃើញ ជំនាន់ខ្មែរក្រហមមិនដែលស្គាល់មុខទេ ទើបឃើញតាម៉ុក ។

យិនៈ ឲ្យកាត់អាអ្នករត់ហ្នឹង?

ហោះ បាទ កាត់អ្នករត់ហ្នឹង ដូចថាជាប់ ដូចថាដែលរត់ ដូចអីអត់ឲ្យទៅទេ ។ ឲ្យជិះឡានទៅបញ្ជាកាត់នោះហ្នឹង ។ ឲ្យនៅនោះឯងឲ្យតារិតប្រធានក្រសួងនេះឯងរៀបចំជាក្បួនទ័ពសារឡើងវិញដើម្បីតបតជាមួយយួន ។ ហើក៏នៅនោះឯង នៅកាក់នឹងអមលាំងតំរង់ផ្លូវ ។ ខ្ញុំនៅរត់ទីនោះ វៃម៉េច វៃតល់ខែ៤ ដាច់ដោចទៅមកខត្តុន្ត កំពង់លួងមិនដឹងប៉ុន្មានដើងប៉ុន្មានសារមកដល់លើកក្រោយនេះវាបុកម្តងទៀតឡើងឱរ៉ាល់ ។ ខ្ញុំឡើងដល់ ឱរ៉ាល់ចឹងទៅអត់បាយក្រហាយទឹកពាយប៉ាថ្ងៃក៏គិតគ្នាម៉េសចុះ គេឲ្យនៅខាងកាំភ្លើងធំ ។ ថានៃបាត់មេបាត់កើតគេចាត់តាំងមេថ្មីហើយ ចុះធ្វើទាហានម៉ាលើកទៀតហើយនោះ បើកាលពីដើមទាហាននោះហើយកម្មករ ដល់កម្មករនេះក៏ធ្វើទាហានម៉ាសារទៀតហើយ ធ្វើកូនទាហានគេម្តងហើយ ។ គេថាឲ្យនៅកាន់កាំភ្លើងធំ ។ ក៏ដើរលីធំកាំភ្លើងធំចឹងទៅ ក៏វៃទៅវៃមកចឹងដល់យួន អាំសវៀតណាមដេញចឹងទៅក៏ឡើងភ្នំឱរ៉ាល់ចឹងទៅ ។ ខ្ញុំនេះកើតពិសដើងវាហើមកំពង់ខ្នងដើង ។ គាត់ផត់គាន់និយាយទេ ដល់នេះទៅបានដេកយប់ កាលហ្នឹងអត់បាយទាំងអស់ ។ ព្រឹកឡើងចុះមកក្រោម ដល់ចុះមកក្រោមភ្នំវៀតណាមនៅជុំវិញហ្នឹង ។ ទៅពីអន្កាល់ ខ្ញុំដូចឆ្វល់មិនដឹងទៅច្រកណាច្រកណើវាស្ទាក់មុខ ។ កំពុងតែចុះពីដើងភ្នំចុះរូទៅមានភូមិមួយដើងភ្នំចេះទៅក៏កាត់ដើររកអង្ករតាមផ្ទះប្រជាជន ។ ប្រជាជនរត់អស់ហើយភ័យនោះ ។ ក៏រត់អង្ករខ្លះគេចាប់មាន់វរៈគេ ពួកខ្ញុំនេះអត់ទេ ចាប់មាន់ចាប់អីបានគ្រាន់ ។ អត់ទ្រាំ ដល់ថ្ងៃម៉ោងប្រហែល៩-១០ វៀតណាមវាបាញ់ដូវិតបញ្ចស់សារដើម ភូមិវានៅនោះ ។ ក៏ឯងឡើងភ្នំ ចុះខែ៤ ខែចែត្រហើយពេញក្តៅហើយ ។ បញ្ចេះនោះបញ្ចេះព្រៃកប្បាសព្រៃអីក្តៅអត់មានទឹក ។ ក៏ដល់ហើយ ដល់ចឹងក៏មានវរសេនាតូចដែល គេចាត់ម៉ាសារនោះនៅអមលាំង ឈ្មោះនៃប្រធានវរសេនាតូចឈ្មោះតាអាំ គាត់បញ្ជាថាឡើងភ្នំវិញពួកមិត្ត ។ ឡើងភ្នំវិញ ។ ខ្ញុំថាបាទបង ។ ឡើងផ្លូវណា ថានៃឡើងផ្លូវនេះ ប៉ុនគាត់នោះរត់មុន ។

ឃិនៈ  គាត់ហ្នឹងរត់មុន?

ហោះៈ  រត់មុនចឹងទៅ ខ្ញុំថាបងលឹម បងលឹមហ្នឹងប្រធានកងខ្ញុំប្រធានកងខាងកាំភ្លើងធំ ខ្ញុំទៅអត់រួចទេ មនុស្សងងឹតមុខឈឹង បើអត់បាយអត់អី បើដាច់ទឹកទៅអត់រួចហ្នឹង ។ ធ្មើមុខស្មេញ វាដុតបញ្ចេះ ដល់វាក្តៅដល់កំណត់ ។ ម៉ោង១០-១១-១២ ក្តៅមែនទែនងងឹតហ្នឹង ដាក់ក្តិតអង្កុយក៏មានទ័ពគេម៉ាចំនួន ពួកខាងលើហ្នឹងគេនៅខាង១៦៤ ខាងជើងទឹកខាង កំពង់សោម ។ មិនដឹងម៉េចបានវារត់ ។

ដារ៉ាៈ  ១៦៤?

ហោះៈ  បាទ នាំទ័ពគេម៉ាចំនួនរត់ថតក្រោយវិញ គេថាទៅណោះជួបឃួន ឥឡូវរត់កាត់មកខេត្តកំពង់ស្ពឺវិញ មកខេត្តកំពង់ស្ពឺ ។ ក៏ឈ្មោះមិត្ត អេនៅកំពង់ចាមជាមួយខ្ញុំនឹងឯងតែពីរនាក់ថា ចុះម៉េចយើងទៅមុខ ឬទៅក្រោយ នែគេទៅចោលអស់ហើយ បើថាទៅមុខ ទាល់តែគាមឲ្យទាន់បើថាមិនទាន់ទេ ទៅក្រោយតាមគេ ។ ខ្ញុំថាអត់ទៅទេ ទៅក្រោយវិញចោលអាវុធខ្ចិលនៅ ។ ទេមិនមែនដូនតាយើងទេអាវុធក្រវ៉ាត់ទាំងអស់ កាំភ្លើងធំ ។ អាកាំភ្លើងធំខ្ញុំដេការ៨២ ហើយនឹង៨០សុទ្ធក្រវ៉ាត់ចោលលើភ្នំ លេងមកក្រោយវិញតាមពួកនោះ ។ តាមពួកនោះ ដល់តាមមករកទឹកអីផឹកគេយកអង្ករមកគេដាំបាយ ។ អូ ថាវាដូចត់អារឿងអត់ទឹក ។ មនុស្សថាសំខាន់រឿងទឹកអត់បាយ៣ថ្ងៃអត់អីទេ ។ ខ្ញុំដល់ផឹកទឹកនោមឯងនៅភ្នំនោះឯង ។ ខ្ញុំទៅអត់រួច ខ្ញុំបានបំពង់ទឹកមួយប៉ុនអត់មានទឹកដាក់ ។ ខ្ញុំស្តាយដាប់អើឈ្មោះភានោះថាចុះពីភ្នំមកស្រណោះឯង ឯងនៅលើកំពូលភ្នំគេទៅអស់អាលឹង ខាងណោះក៏គេទៅ ខាងណោះក៏គេទៅ ។ វាថាទៅមិនទៅ និយាយលែងឮខ្សាវ ថាភាឯងចាំខ្ញុំផង ។ ទាញវីងមកប្រលិតនោមមកក៏ស្វាត់តែម្នាក់ ក្រេបវឹបទឹកនោមឯង គិតទៅជាតិទឹកនោមជាតិអំបិលគ្រាន់លេបទៅ វាបានជាតិសើមក្អើកសើមកករត់វីងចុះពីភ្នំតាមគេ ។ តាមតាន់ទៅដល់ជ្រោះមួយគេថា ឥឡូវមិត្តឯងទៅមើលជ្រោះនេះមានទឹកអត់នៅបាតជ្រោះ អានោះគេគោងវ៉ារ ឃើញចុះទៅដល់បាតអត់មានទឹក អូដាច់ខ្យល់ង៉ាប់ហើយមើលទៅយើង ហើយអត់ហ៊ានទៅជិតភូមិ វៀតណាមនៅទាំងអស់ភូមិ តែហ៊ានលេចបាញ់ង៉ាប់ចុះម៉េចក៏ដើររក រកទៅចុះទៅម៉ាកន្លែងទៀត អាពីក្រោមស្រែកថា ទឹកមានហើយ ។ រូធ្លាក់រូហ្នឹងដូចស្វាចឹង ។ រូង១ទឹកហើយក៏ដេកនឿលឲ្យវាជ្រាបឆ្អែះទឹក ហើយបាននាំគ្នាដាំ

បាយដាំអី ក៏ដេកនៅកណ្តាលព្រៃដេក ។ ដេកកណ្តាលព្រៃចឹងទៅស៊ីផ្លែឈើម៉ាយប់ សគ្រាំ ស៊ីឡើងបានគិតថា ខេត្តកំពង់ស្ពឺចុងហើយឥឡូវយើងដើរសំដៅ អត់ស្គាល់ពោធិសាត់ យើងកាត់ មិនមែនថាកាត់វៀតណាមណា និយាយតែយួន កាត់ខ្សែទូរសព្ទ័ ។ ហី សត្វនេះឯងតែទៅនៅកន្លែងណាគឺខ្សែទូរស័ព្ទរហូត ។ កណ្តាលព្រៃភ្នំក្រំថ្មក៏រាយ ខ្ញុំឆ្ងល់មិនដឹងជាខ្សែប៉ុន្មានលានខ្ញុំឆ្ងល់ដល់ហើយទៅកាត់ៗមកក៏ធ្លាក់នៅខាង ណេះវាត្រពាំង ដូរទៅពីអមលីងចឹងទៅ វាកំពង់ដួរនៅភូមិចេស អានេះដូវក្រឡុក អានេះដូវលំ ទៅនៅគុម្ពឬស្សី អត់ហ៊ានកាត់ទេ ព្រោះផុតពីគុម្ពឬស្សីវាល វាលទៅ វាលស្រែចឹងទៅ បានដុះភ្នំមួយទៅឆ្ងាយដែរ ម៉ាគីឡូដែរ ។ ចុះអត់ហ៊ានឆ្លងផ្តេសផ្តាសទេខ្លាចក្រែងយុវជនឃើញមកបាញ់ផាប់ រត់អត់រួចក៏អង្គុយ អង្គុយម៉ាសន្ទុះព្រួឡាន ។ ឡានមកហើយ ឡានយួនមកហើយ ។ ពួនៗគុម្ពឬស្សីលក់ អាពួកយើងខ្លះថាបាញ់ទៅ ទេកំបាញ់តែបាញ់បែកការណ៍លែងតែខុស អីផាប់ហើយរត់អត់រួចទេ ។ មិនដឹងទៅណាទេ ព្រោះអត់បាយផង ។ ក៏អត់ហ៊ានបាញ់ទេឡានជិះព្រាត អត់ដឹងទេវៀតណាមទៅ ដល់ប្រជុំដួរ ។ ឲ្យពីរនាក់ទៅស៊ើបការណ៍ក៏អស់ឡានអស់ ស្ងាត់អត់មាន ។ ឥឡូវឆ្លងៗរឹបកណ្តាលថ្ងៃ ឆ្លងរឹបរត់ទៅកាត់ភ្នំចេសទៅ មានភ្នំតូចមួយល្វាច ទៅដេកលើកំពូលភ្នំ ភ្នំនោះអត់មានស្លឹកឈើអីទេ ដេកអត់បាយហ្នឹង ក៏អើតទៅឃើញភ្លើងផ្លុងៗ ព្រុសូរកាំភ្លើងវៀតណាមបុកទៅចុះវិញ ។....? ដេកម៉ាយប់ព្រឹកឡើងកាត់សំដៅទៅថាទៅខេត្តកំពង់ស្ពឺទៀតថាមកក្រោយ ។ គិតថាបកក្រោយវិញ អត់បានទេទៅមុខអត់បានទេ ឥឡូវយើងក៏បកក្រោយ ។ ក៏បកៗទៅដើរម៉ាព្រឹកដល់ម៉ោង១១ ដូចថាព្រៃភ្នំចុះក្រោមចេះតែចុះៗយូរឃើញឃ្វាលគោ យូរឃើញគោហ្វូង អូជិតដល់ភូមិហើយ ។ ពឹតឲ្យលឿន ដល់ទៅតិចទៀតឃើញប្រជាជន អូបានបាយហូបហើយ ។ ដល់ជួបប្រជាជនសួរទៅថា ភូមិនេះយួនចូលនៅថានៅ ។ អូ អុំដាច់បាយ បើបានបាយជួបគ្នាមិនដែលស្គាល់គ្នា ខ្លះហើយអែអុកហើយបានបាយទឹកហូប ស្មើប្រហែលជាម៉ោង៥ វៀតណាមបុកមកទៀតលេចទៀត យីទៅខាងណាទៅខាងណា ។ ក៏រត់បែកបាក់គ្នាទាំងយប់ហ្នឹងទៀតហើយបានហូបបាយម៉ាពេល ។ ឆ្ងាញ់ណាស់នៅនឹងភូមិក៏បែកបាក់ ត្រឡប់ត្រឡិនទៀតខ្ញុំម៉ាយប់បែកពីគាត់នោះហែ្សងនៅនោះទៅ ។ ក៏នៅជុំគ្នាជាមួយភា គេនៅកំពង់ចាម ភា នោះគេមានប្រពន្ធហើយ កាលនៅស្រុក គេចំនាស់ជាងខ្ញុំ ។ ទៅដល់ជួបហ្នឹង

ដល់ព្រឹកឡើង ថាយើងគិតម៉េចបើយើងបែកគ្នា ។ យើងអង្គុរអត់ក៏អត់ ក៏ដើរទៅៗស្រាប់ឃើញនារីម៉ាក្រុម ជិត៤០នាក់ នារីកម្មករ ។ កម្មករដូចខ្ញុំដែរ ដែលរត់ចេញពីភ្នំពេញទៅគេនៅម៉ាក្រុមគេ គេដល់សហករណ៍មុនគេបានស្រូវគេបោកគេធ្វើជាអង្គុរ ធ្វើជាអង្គុរទៅគេហុង ហើយគេអ៊ុតថង់ជ័រធ្វើជាក្រម៉ាយកមកហុងទៅ ម៉ាហុងមានតិចអី ប្រហែលម៉ាតៅម្នាក់ ។ ក៏កម្មករប្រុសៗនោះសុទ្ធតែគូដណ្តឹងគេ ប៉ុនអត់ទាន់បានរៀបក៏រត់មក ។ រត់តាមគ្នាវាមកបីបួននាក់ គ្រាន់តែនារីជាង៣០ ហើយសួរខ្ញុំថា ពូ ពូហ្អែងកងទ័ព ។ ខ្ញុំថាបាទទ័ព ដែរ ទ័ពខ្ញុំនេះអត់ដឹងមុខទេ មិនដឹងជាទៅណាទៅណើទេ បើអត់មេអត់កើយ ។ បើថាទិសដៅខ្ញុំមេគេថា ឲ្យទៅជួបគេនៅបរវិលបាត់ដំបង មិនដឹងណាបាត់ដំបង ។ គេថាឆ្លងអាឡាក់កងដើង ។ អូ ចឹង ពូខ្ញុំសុំដោយសារផង ខ្ញុំកម្មករនៅគីឡូលេខ៦នេះ ខាងកៅស៊ូក្រែប ។ អើចុះមានអីធ្វើដំណើរទាំងអស់គ្នាខ្ញុំអត់អង្គុរ ។ ក៏ចូលរួមដើរទៅដូចបងដូចប្អូនរាប់អានគ្នាចឹងទៅសំណេះសំណាលដឹងសុខដឹងទុកទៅ ។ គេថាឲ្យពូហ្អែងធ្វើប្រធាននាំផ្លូវខ្ញុំដើរតាមពូឯង ពូហ្អែងទៅណាខ្ញុំទៅហ្នឹងដែរ ។ ទៅហើយ ។ បងហ្អែងទៅបានដេកផ្លូវពីរយប់ពីរថ្ងៃដល់ប្រវត្តិកំសត់ម៉ាលើកទៀត ដែលគេត្រូវយកទៅវៃចោល នៃអត់ដឹងខ្លួននៃនិយាយរត់ទៅ ទៅដល់សហករណ៍នោះ ។ ទៅដល់ចេសថ្ងៃល្ងាច រត់ជាមួយនារីៗអង្គុរវាច្រើនម៉េច ម៉ាទ្រនូលម្នាក់ៗ ។ បើប្រុសៗច្រកខាងខោគេ ខោកម្មករគេបើកឲ្យ ក្របួចដើងចេសមកច្រកខាងណេះៗដូចទៃចឹងស្ពាយក្រោយ ។ ក៏ម្នាក់ៗអង្គុរចឹងទៅ ខ្ញុំក៏ ជួយទូលជួយនេះគេដែរឯងបងគេ ។ ដល់ទៅដល់កណ្តាលព្រៃមានជ្រោះមានពើងថ្ម យប់ហើយ យើងទៅណាទៀតបើយើងអត់ស្គាល់ផ្លូវ ។ ហើយរត់នេះមនុស្សអត់ទាន់រត់ទៅច្រើនទេមានតែយើងមុនគេ ក្រែងយើងទៅមុនទើបផុត មិនដឹងជាផ្លូវនេះទៅណាទេ គិតសម្រាកនេះ យើងភាពគ្នាសម្រាកនេះ នឹងថ្មនេះព្រោះមានជ្រោះមានថ្មមានទឹក ទេស្រេចនឹងពូបើថាសម្រាកនេះក៏សម្រាក ។ នៃយេស វាអត់ដឹងថាអាពួកសហករណ៍នោះ វាយកប្រជាជនទៅធ្វើក្តួចធ្វើអីពើលើ ដូចថាល្អាងខ្មោចចឹង វាមានផ្លូវពីដើងមួយ ដល់មាត់អូរចេសវាយកប្រជាជនទៅធ្វើការនោះ ។ ដល់ជិតយប់វាលើកទៅបាត់ ។ ពួកខ្ញុំ អត់ដឹងដល់អត់ដឹងចឹងក៏នាំគ្នាដាក់អង្គុរអី រកដាំបាយអីសម្រាកហើយ ។ ពួកនោះមិន ដឹងមកពីណាពីរនាក់ស្ពាយកាំភ្លើងវាមកពីភូមិឯងមិនស្គាល់ផ្លូវ ។ វាដើរមកហួស ដល់នេះ វាដើរមក

វិញ ។ វាថាពួកបង១អញ្ជើញពីខាងណា ។ សួរចឹង ខ្ញុំថា បងនៃមកនេះ មានទិសដៅមានដែរ ប៉ុនវាអត់ស្គាល់ផ្លូវ ទិសដៅក្រសួងនោះ ខ្ញុំកម្មករទេ អត់ឆ្លើយថាខ្ញុំ មានទាហានមានកាំភ្លើងមានអី ។ ខ្ញុំកម្មករទេ ប៉ុនទិសដៅទៅបាត់ដំបងទៅបរវិលព្រោះគេ ថា ទៅបរវិលគាល់ឆ្លងអាឡាក់កងដើងអីណាណោះបានទៅរួច ។ បើទៅណោះក៏ប៉ះយួន ទៅណោះ ក៏ប៉ះយួនដែរ ទាល់តែទៅអាឡាក់កងដើង ។ អូ មិនអីទេទៅសម្រាកកន្លែងខ្ញុំ ចាំ ខ្ញុំនាំផ្លូវព្រឹកឡើង ។ ក៏ឯងណោះជឿហើយ អត់ដឹងអីដែរស្មានតែវាស្រួល ។ ម៉េចមិត្តនារី ទាំងអស់គ្នាទៅសម្រាកកន្លែងគាត់ចុះ ។ ចុះកន្លែងនោះឆ្ងាយប៉ុនណា យើងទៅតែតិច ដល់ តែ ១០០ម៉ែត្រ២០០ម៉ែត្រ ។ សម្រាកនេះមិនបានទេ បងឯងដឹងដែរព្រៃនេះសុទ្ធខ្លាតូចខ្លាធំ មកសម្រាកអីកណ្ដាលវាលនោះស្រេចហើយ ។ ទៅណោះទៅមានអ្នកការពារ ក៏ជឿលុង ចឹងបានខ្ញុំថាអាពួកនេះខ្លាំងណាស់ ពួកអាក្រោយវៃឆៅ១មែនហ្នឹង ។ បងឯងខ្ញុំកាលណោះមានកាំភ្លើងម៉ាដើមដែរ កាលមកពីមកពីកាំភ្លើងធំបែកមក មានកាំភ្លើងម៉ាដើរដែរកាប៊ីននោះ១ សម្រាប់ការពារកាំភ្លើងធំបាញ់សត្វអីស៊ី ។ ក៏អត់មាន ប៉ុនខ្ញុំមាន ខ្ញុំបាញ់ ម៉ាគ្រាប់ខ្ញុំដាក់ត្រង់កន្លែង ។

## កាសែ្សតទី២

ថាត: ដល់ទៅដល់កន្លែងវាអិញ្ចេះទៅក៏ស្រាប់តែឃើញប្រជាជនអីប្រក់កៅស៊ូប្រក់អី....ក៏វាងងឹតហើយនោះនេះបងនេះដក់អង្ករដាក់អីនៅត្រង់នេះតែម្ដុំហើយត្រង់នេះជុំគ្នា ក៏ស្រាប់តែវាឆ្លងអាតាមថ្នល្អាងដូចយើងទៅគូលេននេះឯងណា៎ ឆ្លងអិញ្ចេះទៅក៏មេគេ ឃុំសង្កត់គេនោះទៅជួបប្រាប់ដល់តែប្រាប់មួយសន្ទុះក៏ស្រាប់តែឃើញវិទ្យុមួយមកស្អីមិនដឹង ប្រធានសង្កាត់គេហើយមើលទៅក៏កូនទាហានគេមកព្រាត៨នាក់ ឈ្លបគេ សុទ្ធតែកាំភ្លើង អាសេសេសេអីគេហឹមើលកូននេះបែបបែកគ្នាហើយមកវាឃើញ នយោបាយស្រួលអីចេះទៅ អរ! នយោបាយរបស់ខ្មែរក្រហមវាស្អាតមែនដល់អីចេះទៅបងឯងណែ កំលាំងដែលមកទាំងអស់នេះមានអាវុធប៉ុន្មានដើម ខ្ញុំថាដែលមានអាវុធ ឃើញស្រប់ហើយសុទ្ធតែនារី មានអាវុធខ្ញុំមួយដើមនេះ ឥឡូវអិញ្ចេះទៅដើម្បីកុំអោយពិបាក ដើម្បីរក្សាសន្តិសុខ ខ្ញុំណែមិនថាម៉េចទេខ្ញុំសុំអាវុធបងឯងទៅដាក់កន្លែងបងនោះទៅ ចាំព្រឹកឡើងខ្ញុំជូនបងឯងធ្វើដំណើរទៅក៏យកទៅវិញចុះ ខ្ញុំនឹកឃើញថា កុនហើយ ខ្ញុំដឹងមិនមែនខ្ញុំមិនដឹងទេ ខ្ញុំដឹង

ថានេះដានយោបាយហើយ តែដកអាវុធបានប្រាកដដាធ្វើវិធំសនាវណាមួយហើយ ឥឡូវនេះមែនៗ ខ្ញុំនឹកឃើញថាមិនអោយក៏ខ្ញុំមិនដឹងធ្វើម៉េច បើចេះក្នុងវំលងគេហើយ យើងទៅរត់ម្នាក់ឯងអាគ្នាប៉ប្រឹករត់ម៉េចរួចអារត់ទៅយើងមិនដាច់ស្បៀង យើងមានស្គាល់ផ្លូវឯណាសព្វព្រៃភ្នំសព្វព្រៃគេៗ អោយក៏អោយទៅដល់អោយអាវុធទៅ ចេញម្តងទៀតទាំងមេទាំងកូនគេវាបានអាវុធដឹងថាឡើងកណ្តាប់ដៃវាហើយ ឥឡូវអីចេះមានកៅស៊ូធំលាតមកអង្ករនេះចាក់ទាំងអស់ខ្ញុំថាអរដល់បាត់ ហើយសុំអីគេថង់សំពាយខោអាវអី ខ្ញុំថាដល់បាត់ៗនារីៗក៏ទើហេ!ឆែកយ៉ាងម៉េចខ្ញុំមិនអោយឆែកទេ អង្ករខ្ញុំលាក់ម៉េចកើត ស្លាប់ហើយខំធ្វើអង្ករមកធ្វើដំណើរ ក៏វាចេញដំណើរតែម្តង វាថាផែនការណ៍ ឥឡូវអាក្មេងហ្អែងចាត់ការអាណាដែលថាដើងខ្វាំង បើថាមិនកើតយកទៅដាក់នៅដើងភ្នំបាន១ ២ទៅៗ ឯងថាយ៉ាស់ធ្វើបាត់រឿងហើយពេលនេះ យំម៉ងនារីដល់ថ្នាក់យំៗ ខ្ញុំនឹកឃើញស្រណោះខ្លួនក៏នឹកឃើញចិត្តមួយខឹង ខ្ញុំគប់គ្រាប់បែកទៅក្រែងលវាងាប់ទាំងវាងាប់ទាំងឯង ហើយនារីនេះប្រាកដដារត់មិនរួចបើសិនដាថានៅរស់វាអាចចាប់បានសម្លាប់ទាំងអស់ អត់មានសល់មួយទេ អ៊ីចឹងខ្ញុំសុខចិត្តរណបវាចុះចាញ់ហើយនយោបាយវាចាញ់វា ចាក់អង្ករ វាធ្វើមែនទែន ចុះគ្នាស្មានតែតិចណាស់គ្នា៣០នាក់...ចាក់ទាំងអស់សរុបទុកអោយតែមួយគី ព្រឹកឡើងជូនទៅ ជូនទៅវាបង្ហើបពាក្យថា ហ្អែងជូនទៅអាពីរនាក់ អញទៅខាងក្រោយ ទៅកន្លែងសហករណ៍ណា បងធំទៅមើលៗអាណាទ្រើសៗទុកវា ចោលបានមួយពី អីយ៉ាស់ក៏ឯងមាននិយាយអីរឿងអាវុធមិនសំណំអោយឯងវិញអត់ ឡើងកណ្តាប់ដៃវាទាំងអស់ ខ្ញុំថាទេបានកណ្តាប់ដៃខ្វាទៀតហើយ គុនដល់កន្លែងចៅហ្វាយស្រុកមានកាំភ្លើងខ្លីមួយ មានម៉ូតូសេអិលមួយទៅនៅបាន២យប់២ថ្ងៃបានគេហៅប្រជុំយប់ឡើងហៅប្រជុំ ឯណាពួកមិត្តដែលថាទៅបរិលហៅមកទាំងអស់មកដល់ហៅទៅក៏អង្គុយត្រៀប ក៏គេអង្គុយនៅលើនោះឯងនិយាយ ពួកមិត្តឯងនេះដំណើរនេះ ដំណើរទៅណា គ្មានអ្នកណានិយាយទេ មានតែខ្ញុំខ្ញុំថាខ្ញុំកម្មករទេ ប៉ុនដំណើរខ្ញុំ ក្រសួងខ្ញុំទៅអស់ហើយ គេរត់ទៅនៅបរិលបាត់ដំបង តែគេអោយខ្ញុំបើថាកំលាំងក្នុងក្រសួងពាណិជ្ជកម្មទាំងអស់ដែលរត់ចេញពីភ្នំពេញទៅ ធ្វើដំណើរទៅក៏អោយធ្វើដំណើរទៅតាមអាលាក់កងដើងហើយទៅជួបនៅអាដែងបរិល ក្នុងខេត្តបាត់ដំបងក៏ខ្ញុំមកតាមទិសដៅនោះឯងបងៗ ពូឯងសុទ្ធពួកខ្វាំង ថាអិញ្ចឹង មើលអញសួរថា

អាណាថាភ្នំពេញយួនចូល អញទើបមកពីប្រជុំមិញនៅត្នោតពង ថាអិញ្ចេះ មានយួនអាណាមកពីអន្លង់ ហើយហ្អែងនេះពួកខ្មែរបំផុសពួកប្រជាជនពួកចលនាខ្មាំងបង្កប់ ដាក់របបគ្នា ៤០ នាក់អន្លង់រពាកំប៉ុងអន្លង់ទឹកភ្លុកដល់ម៉ងខ្ញុំឆ្នាំងខ្លះមួយអន្លង់រពាកំប៉ុង ព្រឹកឡើងបើកអោយពាកំប៉ុងអន្លង់រងងខ្ញុំស្រណោះនារីៗទ្រាំអត់ខ្ញុំខ្លោចចិត្តអត់ហូបណា៎វាអន្ទុយអីហែក ក្រណាត់ធ្វើអីហៅមកហូបថ្ងៃឡើងអីវានឹកឃើញស្រណោះ ឯងឪពុកនោះ ចុះធ្លាប់តែហូបឆ្អែតនៅភ្នំពេញណា៎ដល់វាទៅអិញ្ចេះទៅអន្លង់រពាកំប៉ុង បបរមួយខ្លះត្នោតអិញ្ចេះទៅ មិនដឹងជាអីណាអីណីអ៊ូដល់កម្មហើយយើងថ្ងៃណាវា យកទៅធ្វើស៊ីហើយមើលទៅ ហើយអត់អោយទៅទេទៅមុខទៅក្រោយគឺអត់អោយទៅទេ អោយនៅផ្តិត្នាឯងប៉ុន្មាននាក់ អត់មានប្រជាជនចូលទេៗ ខ្ញុំថាដល់ហើយ ដល់ថ្នាក់នឹងពួកអាអស់នេះវាធ្វើស៊ីហើយ...ដល់មេធំវាថាឯងខ្មាំងបង្កប់អីណាស៊ីរូបផ្ទៃក្នុងវានៅបានប្រហែល២៣យប់ ក៏ថ្ងៃស្អាលនេះឯង ក៏ស្រាប់តែដល់ក៏ឃើញមានមនុស្សមករប៉ុយៗតាមផ្លូវនោះឯង ទ័ពចេញមុនដំបូងមួយៗ ក៏ខ្ញុំស្រម៉ៃ...ខ្ញុំថាធ្វើទ័ពយូរណាស់ ហើយវាដាច់ចាញ់......ក្រោយ ប៉ុនគិតតែចិត្តឯងមិនហ៊ាននិយាយទេណា៎ដល់ពួកទ័ពមកដល់ក៏គេដាក់ដាំបាយ ខ្ញុំឃើញគេដើរទៅលេង មកបងហូបបាយហើយយើងឃ្លានហើយក៏ហូបនឹងគេទៅ ពេលបងខ្ញុំបងណាដែលប្រធានកងខ្ញុំចង់ជួប ខ្ញុំចង់ជួបអីបេះទៅក៏បងឯងមានការអី អត់ទេខ្ញុំចង់ជួបគាត់បន្តិចប្រាប់ពីរឿងខ្ញុំហ៎ោមានអី គាត់នោះហើយ ស្តាយឆ្នាំងបាយនោះហើយ ប្រធានវរៈសេនាតូច កាំភ្លើងខ្លីអត់មានហ៊ានស្តាយទេដាក់សៀតតែហ្នឹងចង្កេះទេ ក៏នាំខ្ញុំទៅនៅមាត់អូនោះឯង ក៏ខ្ញុំប្រាប់ហេតុការណ៍នោះឯងហឺបង ខ្ញុំនិយាយប្រាប់ពីដំណើរទំនងតាំងពីដកអន្លង់អី គេប្រម៉ាតខាតទាន ដកកាំភ្លើងហើយក៏ អាក្មេងហ្អែងចាត់ការដកកាំភ្លើងមក អាណាដើងខ្លាំងទៅជាមួយខ្ញុំចង្អុលមុខប្រាប់ខ្ញុំថាស្រេចបាត់ៗ ទៅដល់ក៏យីគិតទៅអាសត្វទ័ពខ្លាំងខ្មែរក្រហមទៅដល់ឃុំខ្ទោកជុំវិញរោងអាប្រធានចៅហ្វាយស្រុកគេមិនដឹងនៅតែម្នាក់ឯង នៅតែនារិសាម្នាក់ប៉ុណ្ណោះឯង ក៏គាត់ហូតកាំភ្លើងខ្លីពីចង្កេះ ក៏អាប៉ុន្មាននាក់បេទៅរេពេញរោង ចុះមកចុះមកជីផ្លូវ អាវុធដែលដករបស់គេទៅអីណា បាទខ្ញុំបញ្ជូនទៅថ្នាក់លើ មិនអីទេចាំខ្ញុំទៅយកអោយ គាត់វិញៗ ជាន់កល្បេចបានមានសិទ្ធអីមកដកអន្លង់ដែលគេធ្វើដំណើរប្ញហ្អែងនេះហើយ ដែលថាគេបង្កប់ស៊ីរូងផ្ទៃក្នុងណាសុទ្ធតែទៅប្រជុំនៅត្នោតពងមើលហ្អែងទៅប្រជុំពីថ្ងៃណា? ហ្អែងថា

អត់មានឃ្លួនចូលមើលហ្វែនប្រជុំពីថ្ងៃណាមើលហ្វែនចុះមកដីអត់ហ៊ានចុះនៅ...រួច ក៏តាំង ហើយយកអង្ករពីតឹមកអោយអង្ករចាំខ្ញុំបញ្ជូនមកអោយក្រោយ បើអត់យកមកអោយ មួយដើមហើយនិងអង្ករប៉ុន្មាននេះអែង ហ្វែនអត់រួចខ្លួនហើយអិញ្ចេះមិត្តនារីអែងហើយ និងបងៗប្អូនៗនេះឯងដែលមានដំណើររួមគ្នានេះ ចេញទៅមុនខ្ញុំទៅហើយបើ ជួប ប្រជាជនបើជួបមានដំឡូងអី សុំគាត់តាមដំណើរសំរាប់ជាស្បៀងទុកធ្វើដំណើរទៀត ។ ចាំខ្ញុំអ្នកនៅការពារ ចាំមើលអាណាដែលថាដើងខ្លាំងទៀតទុកអោយខ្ញុំ ខ្ញុំធ្វើ...ហ៊ុំរួចខ្លួន ពេលនោះហើយ ខ្ញុំថាកុំអោយតែបានប៉ុណ្ណោះងាប់ហើយខ្ញុំវាវាយចោលក៏មិនដឹង ហ៊ុំពួក នេះអត់មានធម្មតាទេ ។

ដារ៉ា: ហើយដល់ពេលណាបានចូលដល់ភូមិ?

ថាត: អ៊ូ!មកភូមិនេះនេះ?

ដារ៉ា: បាទ ។

ថាត: ចូលក្នុងឆ្នាំ៧៩ដែរ ។

ដារ៉ា: តែនៅខែណាថ្ងៃណា?

ថាត: ខែ៧ខ្ញុំ ។

ដារ៉ា: មកដល់ភូមិវិញ?

ថាត: រួចគេនោះមកដល់មុនខ្ញុំ ។

ដារ៉ា: អ៊ីចឹងពេលដែលចេញទៅតស៊ូមុនដំបូងឆ្នាំណាដែរពូ?

ថាត: ទៅពី៧២ នេះអែងតាមមើលទៅ ។

ដារ៉ា: មូលហេតុអីបានទៅ?

ថាត: មូលហេតុនោះគឺថា កាលដើមតាមកគ្គាថាសម្តេចឪរត់ចូលព្រៃម៉ាគីដើម្បីតស៊ូអីចេះទៅណា ក៏ជឿជាក់ទាំងគេទាំងឯងនេះថាអើបើសម្តេចលោកមានទុក្ខ រួចយើងជាកូនជាចៅត្រូវតែ ទៅជួយ ហើយការពារប្រទេសកុំអោយគេជាន់គេឈ្លី ហើយកន្ទេមក របប លន់ ណុល នេះឯងបានធ្វើរដ្ឋប្រហារសម្តេចកន្ទេមក ។

ដារ៉ា: អ៊ីចឹងពូយល់ច្បាស់ពីការជិះជាន់នេះដែរ?

ថាត: បាទ ទេកន្ទងមកនេះឯង នឹកឃើញអិញ្ចេះបានជាខំតស៊ូ វាមិនដឹងចុងក្រោយវាទៅជាត្រឡប់ជាអិញ្ចេះបានអត់ដឹង ។

ដារ៉ា: ចេញពីភូមិ ពូមានគ្នាច្រើនទេ?

ថាត: ច្រើន ទៅច្រើនដែរ ។

ដារ៉ា: ទៅជារបៀបស្ម័គ្រចិត្ត ឬក៏របៀបយ៉ាងម៉េច?

ថាត: កាលដែលខ្ញុំទៅ ខ្ញុំទៅស្ម័គ្រចិត្តទេ ព្រោះបានថាស្ម័គ្រព្រោះណែ៎ ការឃោសនាអិញ្ចេះទៅ វាជនបទយើងតែងឃោសនាទៅ វាអាចជួយជាន័យរបស់វាណា៎ វាផ្សព្វផ្សាយទៅ បើថាយើងមិនតស៊ូទេ ទុកអោយគេមកជិះជាន់គេលេបទឹកដី ហើយពិសេសវានិយាយពីរឿងអាមេរិកកាំង ចេះតែឃើញយន្តហោះអីផងទៅក៏ប្រាកដ ក៏ទៅតស៊ូទៅ ដូចសម្តេចលោកផ្សព្វផ្សាយឆ្នាំ៧០អិញ្ចេះក៏បានទៅ ដល់ទៅៗតាមក្រោយគេ តាមស្តាប់សូរសល់តែ...អីណោះ ខ្ញុំទៅជំនាន់ខ្ញុំ...សុទ្ធតែអ្នកស្ម័គ្រចិត្តទេ ដល់ក្រោយបានគេថាវាទូទៅម៉ងខាងណោះណា៎ ដល់អាយុ១៧-១៨ជាប់ម៉ង ។

ដារ៉ា: ចុះពូចេញមុនដំបូង ពូទៅខាងណាទៅ?

ថាត: ខ្ញុំទៅ...កំពង់ធំ ដល់យូរទៅគេបញ្ជូនទៅសំបូរ...យើងនេះ ទៅចាត់តាំងនៅអីណោះដល់ចេញពីនោះមកបានមកវិកហាត់យោធានៅវត្តស្រងែយើងនេះ ។

ដារ៉ា: ក្នុងភូមិអី ឃុំអីវត្តស្រងែយើងហ្នឹង?

ថាត: ភូមិស្រងែវត្តស្រងែរៀនសូត្រវិកហាត់នេះឯងវរសេនាតូចមកពីវៀតណាមនោះ ឈ្មោះតាអែក ព្រោះគេហៅថាពួកភូមិភាគខាងជើងមានតាអែក នេះឯង...ជំនាន់ចាស់ ពួកនោះកាំភ្លើងបាញ់សុទ្ធតែហាត់ តែរលាស់ សត្វគីគ្គុកចាំមើល ។

ដារ៉ា: ហើយរៀនបានប៉ុន្មានខែ ប៉ុន្មានឆ្នាំបានចេញទៅប្រយុទ្ធ?

ថាត: រៀនបាន២ ៣ខែហើយបានចេញទៅវាយ ។

ដារ៉ា: នៅម្តុំណា?

ថាត: នៅកំពង់ធំនេះឯង..ដល់វាយអិញ្ចេះទៅ ដូចថាពីដើមមានទ័ពតំបន់ទ័ពភូមិភាគ បើទ័ពតំបន់គឺយើងនៅការពារតែក្នុងខេត្តកំពង់ធំ ដល់ទ័ពភូមិភាគ គេថាចល័តពីកំពង់ចាម កំពង់ធំសៀមរាបបាន ក្នុងភូមិភាគវាមាន៣ ។

ដារ៉ាៈ អ៊ីចឹងពូនៅក្នុងទ័ពតំបន់ឬក៏?

ថាតៈ បាទ មុនដំបូងខ្ញុំនៅក្នុងទ័ពតំបន់ ។

ដារ៉ាៈ តំបន់ហ្នឹង តំបន់លេខប៉ុន្មាន?

ថាតៈ ៤០២ ។

ដារ៉ាៈ ៤០២?

ថាតៈ បាទ វាដាក់ឈ្មោះ៤០២ វាដាក់ឈ្មោះ៤០២ មុនដំបូងណា បានចេញពីនោះខ្ញុំ ទៅនៅ ៣០៦ ។

ដារ៉ាៈ ៣០៦នៅក្នុងទ័ពតំបន់ដដែលឬ?

ថាតៈ ទេអត់ទេ ភូមិភាគ ។ ចល័តហើយ វាយកំពង់ចាមទៅ កំពង់ធំទៅ សៀមរាបក៏បានដែរ ។

ដារ៉ាៈ ៣០៦ជាវរសេនាធំ ឬក៏វរសេនាតូច?

ថាតៈ វរសេនាតូចទេ៣០៦ ។

ដារ៉ាៈ កងពលអី?

ថាតៈ ទេខ្ញុំហ្នឹងវានៅជាយុទ្ធជនដែរ ក៏មិនដាកងពលលេខប៉ុន្មានទេ ៣០៦? ខ្ញុំភ្លេចអស់ហើយ ហើយខ្ញុំក៏នៅអត់បានយូរដែរ៣០៦នោះ ។

ដារ៉ា ក្នុងឆ្នាំណាដែលពូនៅ៣០៦ហ្នឹង?

ថាតៈ កាលដែលទៅនោះ៧២ ៧៣ ខ្ញុំនៅក្នុងឆ្នាំ៧៣ ៣០៦ ។

ដារ៉ាៈ អ្នកណាប្រធាន៣០៦?

ថាតៈ ៣០៦ នោះ ចាំតែក្រោយដែលខ្ញុំឡប់មកវិញពី៣០៦ មកចូល៣០៩បានចាំ ។

ដារ៉ាៈ អ្នកណាគេ៣០៩?

ថាតៈ ៣០៩ តាបេង ហ្នឹង ។

ដារ៉ាៈ នៅវរសេតូច?

ថាតៈ បាទ នៅវរសេនាតូច ។

ដារ៉ាៈ ក្នុងចំណុះវរសេនាធំលេខប៉ុន្មាន?

ថាតៈ អត់ដឹងទេខ្ញុំ បើលោក...គេខាងកងវរសេនាតូចគេអាចដឹង បើខ្ញុំនៅជាយុវជនធម្មតា អញ្ចេះទៅនៅវាយនៅសៀមរាប បានទៅនៅវាយនៅសៀមរាបបានឃើញកែ ពកម្តង ។

ដារ៉ាៈ ពូនៅសៀមរាបហ្នឹង?

ផាតៈ បាទ ។

ដារ៉ាៈ ក្នុងឆ្នាំណាដែលពូទៅនៅវាយនៅសៀមរាបហ្នឹង?

ផាតៈ សៀមរាបទៅនៅវាយតាំងពីចុងឆ្នាំ៧៣ ៧៤ក៏នៅតែសៀមរាប សៀមរាប-កំពង់ធំ ។

ដារ៉ាៈ ទៅវាយហ្នឹងជួប កែ ពក កែ ពកគាត់ធ្វើអី?

ផាតៈ ដូចថាគាត់ចុះទៅពិនិត្យទ័ពម្តងៗវាយដូចថាវាយអញ្ចេះទៅ ព្រោះគាត់ក៏និយាយរាប់រៀប ពីប្រធានភូមិ មានដូច កុយ ធួន នេះណា កាលនោះ កុយ ធួន មិនទាន់ឡើង ជានាយក រដ្ឋមន្ត្រីខាងពាណិជ្ជកម្មនោះ គាត់នៅជាប្រធានភូមិភាគបាន កែ ពក គាត់អនុ គាត់ក្តាប់ ខាងទ័ព ខាងទាហានភូមិភាគហើយក្នុង៣ខែអញ្ចេះគាត់ពិនិត្យ ម្តងៗទៅដូចថា ខ្វះគ្រាប់ ខ្វះរំសេវទ័ពណាខ្លាំងណាខ្សោយ គឺគាត់អាចដឹងហើយព្រោះគាត់ចុះជាប់ ធំណាស់គាត់នោះ មាឌមិនធម្មតាទេមាឌម៉្ងតួដាក់ទៅកិតគ្នាហើយ បាទខ្ញុំឃើញម្តងនោះ ឯងកាលនៅវាយនៅ សៀមរាបជំនាន់៨០២ ៨០០អីនោះ វាយជំនាន់នោះហើយទៅ បានវាអោយឡើង វាយសព្វគ្រប់បានសំរាក សំរាករួចអញ្ចេះទៅ គេដកកម្លាំងមួយចំនួន អានោះកំលាំង ពិសេស គេយកទៅវាយនៅព្រំដែនក្នុងឆ្នាំ៧៤ នោះឯងទៅវានៅភ្នំដងរែក ។

ដារ៉ាៈ ទៅវាយថៃ?

ផាតៈ ទៅនោះឯងទៅវាយថៃហៅថាខ្មែរសារិនណា ណែវាចុះមកទាញខ្មែរយើងនៅតាម ព្រំដែន អោយចូលប្រទេសវាដល់តែចូលអញ្ចេះទៅក៏គេអោយពត៌មានមកក៏ វរសេនា តូចនេះឯង គាត់មកគាត់មានបទបញ្ជារសហការណ៍ច្រើនណាស់អានោះ ទៅ២វរសេនាតូច ប៉ុន្តែក្នុងនោះ គេដកតាមកងដូចថាបើអនុសេនាធំ គេយកចំនួនមនុស្សតែមួយអនុសេនាតូចទេ គេយក ទៅជំនួសគ្នាវាយដល់ទៅអញ្ចឹងបញ្ជាការមានតាបេង ហ្នឹងទៅផ្ទះមួយទៅតាហោះ នោះអត់ ទាន់បានទៅទេខាងសៀមរាប ។ ប៉ុន្តែទ័ពគាត់ទៅដែរ វាយរួមគ្នាដល់ទៅវាយនោះឯង ទៅ ជិតកន្លះខែទៅយូរណាស់វាយបានប្រហែលជា៣ម៉ោង អត់មានបានវាយបានអី វាបែក ការណ៍ទៅក៏ឯកឯងទៅត្រៀមចាំថាក្រែងទាហានថៃ ទាហានខ្មែរសារិនវាឡើងមកទៀត ចាំវាយដល់វាអត់ឡើងមកទេ ក៏គេអោយដកទ័ពមកវិញទៅឯកឯង ។ បានដកពីនោះមកក៏ គេបញ្ជូនមកកំពង់ធំវិញ ។ នៅកំពង់ធំ វាយបានមួយរយៈចូល៧៥ហើយ ខែ១ ឆ្នាំ៧៥

ខ្ញុំរបួសជើងខ្ញុំក៏សំរាកពេទ្យ គេថាចាត់ចែងការណ៍អោយវាយទីក្រុងភ្នំពេញ គេប្រមូលទ័ពទាំងអស់នៅក្នុងចំណោមទ័ពភូមិភាគទុកតែតំបន់ដេម្បីការពារតំបន់របស់ខ្លួន ណែចល័តនោះឯងទៅប្រមូលផ្តុំចាំវាយនៅទីក្រុងភ្នំពេញ បើខ្ញុំនោះដេកពេទ្យបានមួយខែពីរខែហើយ អើវាដើរបានកាន់ឈើច្រត់បានហើយក៏វាយកទៅដែរ ។ យកទៅ ឆ្លងទៅខ្ញុំនៅវាយខាងភ្នំបាសិតជាមួយនេះឯង ប៉ុនខ្ញុំអត់បានវាយទេព្រោះខ្ញុំនៅរបួសពិការអត់ទាន់ជាទេ ទៅដល់នោះគេយកតែអ្នកដែលជាជាទៅវាយ អោយខ្ញុំនេះទៅសំរាកពេទ្យនៅភ្នំអគ្គីសណោះ កន្លែងពេទ្យគេនៅណោះ គេអោយទៅសំរាកកន្លែង ភូមិភាគខត្តរអីណោះ ។

ដាវ៉ាៈ អញ្ចឹងមន្ទីពេទ្យនៅភ្នំចិត្តតារីស ហ្នឹងនៅកន្លែងខត្តគ្គហ្នឹងប៉ែ្ន?

ថាតៈ ចូលនោះឯង ។

ដាវ៉ាៈ នៅជិតនឹងភ្នំពេញហ្នឹងដែរហ្នឹង?

ថាតៈ បាទ! នៅក្បែរនោះឯងតើ ហើយដែលវាយមកនៅកិតនៅណោះអីជួរយើងឆ្លងពី ព្រែកក្តាមទៅ ។

ដាវ៉ាៈ ហើយអញ្ចឹងទ័ព លន់ ណុល នៅទីក្រុងភ្នំពេញនៅតែក្នុងភ្នំពេញហ្នឹង?

ថាតៈ នៅក្នុងទីក្រុងភ្នំពេញ ។

ដាវ៉ាៈ ហើយខ្មែរក្រហមព័ទ្ធជុំវិញអស់ហើយ?

ថាតៈ អស់នោះឯង ហើយក៏បុកវាយគ្នារុញទៅរុញមក ហើយខ្ញុំនៅដើរបានមកលេងដល់ ព្រែកលាភ ព្រែកទេសអីសុទ្ធតែទ័ព ។

ដាវ៉ាៈ អីចឹងពូអត់បានវាយជាមួយគេទេ?

ថាតៈ បាទ!របួសគេអត់បានអោយទៅវាយទេ ខ្ញុំនៅសំរាកពេទ្យ លុះដល់គេរំដោះភ្នំពេញ ហើយបានគេមកយកទៀតខ្ញុំ ។

ដាវ៉ាៈ អញ្ចឹងពូអត់បានវាយចូលភ្នំពេញទេ ដល់តែគេវាបានភ្នំពេញហើយបាន?

ថាតៈ គេអោយដូចថាគេអោយនៅកន្លែងដាំបានដូចថាកន្លែងស្នាក់នៅណា៎ ទ័ពគេវាយរុញទៅមុខទៅ ដល់ពេលគេរំដោះភ្នំពេញរួចគេនាំកម្លាំងមកយកទៅនៅទីក្រុងភ្នំពេញនេះឯង ។

ដាវ៉ាៈ ទៅនៅកន្លែងណា?

ថាត: បាទមុនដំបូងនៅគីឡូលេខ៦ នៅបានដូចថា គេលេងសិល្បៈអីរួចហើយដាច់ភ្នំពេញហើយ នៅកំពង់ធំនៅលើកដៃនៅឡើយ នៅរីងនៅឡើយ ដល់គេយកទ័ពមកវ៉ាយបាន២ ថ្ងៃបាន លើកដៃក្រោយគេ ដល់អញ្ចេះទៅគេធ្វើអា១៧មេសាអញ្ចេះទៅក៏ស្រួលបួលគេអោយ ទៅនៅនឹងជ្រោយចង្វា បានកន្លះខែក៏បញ្ជូនទៅកំពង់សោមតែម្តង បាទ!៧៦ខ្ញុំត្រឡប់មក នៅភ្នំពេញ ។

ដារ៉ា: អញ្ចឹងពីការតស៊ូមុនដំបូងមកហ្នឹងពូអត់ទាន់ឮថាអ្នកណាធំជាងគេនៅក្នុងរបបខ្មែរក្រហម?

ថាត: អត់ អត់ស្គាល់ផង ដូចខ្ញុំនិយាយខាងដើមថាបើ...នៅនឹងភ្នំពេញ...កាលគេចាប់ភូមិភាគ អស់ រួចទៅគេរំសាយណ៎ា គេគ្រាន់តែប្រាប់ថាមានបងលេខមួយ មានបងលេខ២ប្រធាន ក្រសួង នោះឯងជាអ្នកប្រកាសក្នុងឆ្នាំ៧៦ បានទាល់តែដាច់៧៦ ចូល៧៧បានឮឈ្មោះ ប៉ុល ពត ។ គាដាក់ឈ្មោះតែម្តង បងលេខ១ គឺ ប៉ុល ពត ។

ដារ៉ា: ហើយបងលេខ២មានដឹងអ្នកណាទេ?

ថាត: ប៉ុល ពត ខៀវ សំផន អៀង សារី នួន ជា គឺមេធំៗទាំងអស់មិនដឹងអ្នកណាលេខ២ទេ ដឹងថា ប៉ុល ពត ហ្នឹងគេដាក់បងលេខ១ ។

ដារ៉ា: ឮឈ្មោះ ប៉ុល ពត ម្នាក់ឬក៏ឮឈ្មោះក្រៅពីគាត់ទៀត មេដឹកនាំ?

ថាត: មានអានេះបើនិយាយទៅវាចែកតាមក្រសួងរបស់វាដែរ មិនមែនអត់ទេណ៎ាតាមក្រសួង បើថា ប៉ុល ពត ជានាយករដ្ឋមន្ត្រីអញ្ចេះចុះ ដល់បន្ទាប់មកនេះ សុន សេន នេះទទួល បន្ទុកខាងកិច្ចការការពារប្រទេស អាដែងក្រសួងការពារប្រទេសខាងយោធា ដល់ អៀង សារី គេខាងក្រសួងការបរទេសការទំនាក់ទំនងក្រៅប្រទេសណ៎ា នោះឯង បាន នួន ជា នេះខាងសភាប្រជាជនគេដាក់អញ្ចឹង ។

ដារ៉ា: កាលហ្នឹងពូដឹងតាមរយៈអី ឬក៏ក្រោយមកបានពូដឹង?

ថាត: ណ៎ែ កាលនោះកាលខ្ញុំមកនៅភ្នំពេញខ្ញុំតែងបានមកប្រជុំ ដឹងថាដឹងអញ្ចឹងម៉ង ដឹងថា ឈ្មោះនេះបាន សុន សេន ខាងក្រសួងការពារប្រទេស នួន ជា ខាងសភាប្រជាជន អៀង សារី ខាងក្រសួងការបរទេស បានតា ជុំ ជឿន ខាងប្រធានសុខាភិបាល នែ៎ ឌុច មួយទៀតនោះខាងផ្នែកកសិកម្ម ហ៊ូ នឹម នៅខាងឃោសនាការណ៍ពត៌មានណ៎ា បានខ្ញុំ លើកថា តាយ៉ុន នេះឯងនៅជាមួយ ហ៊ូ នឹម នៅជាមួយ ខៀវ សំផន ។

ដារ៉ា: ឈ្មោះវិទ្យុអិញ៉ើងអី ដែលថាប្រធានក្រសួងរបស់ពូ?

ថាត: បាទ ។

ដារ៉ា: ឬក៏មានឯកសារអី?

ថាត: មាន មានឯកសារគេថាសម្ព័ន្ធយុវកន គេពេញសិទ្ធរបស់គេណា៎ ចារទុកអ្នកដឹកនាំធំៗ គឺមានបន្តបន្ទាប់គ្នា ។

ដារ៉ា: ពូធ្លាប់បានអានទេអិញ៉ឹង?

ថាត: មើលដែរ ប៉ុនឥឡូវខ្ញុំភ្លេចអស់ហើយដូចវាចូលយើងអីណោះ វាភ្លេចអាពាក្យខ្មែរក្រហម ខ្ញុំមិនចាំ ប៉ុនខ្ញុំបានឃើញខ្លះ ។ ខ្ញុំឃើញ ខៀវ សំផន ផ្ទាល់មុខនៅប្រជុំដូចខ្ញុំនិយាយ នៅខាងដើមថាអាថ្ងៃ៩ នេះឯង ឃើញមុខទៀតគាត់ទៅមើលអាផលសំរិតសំរាំងត្រូវ ចេញទៅក្រៅប្រទេស អានោះដែលខ្ញុំនៅទួលទំពូងណា៎ គេថានេះឯង ខៀវ សំផន រាងគាត់ស្គមអត់មានធាត់ ធំអីទេ រាងស្គមមិនអ្នកដែលធាត់ធំអីដូចគេទេ ។

ដារ៉ា: នួន ជា ដែរ?

ថាត: នួន ជា ឃើញ ។

ដារ៉ា: ឃើញម៉េចដែរ?

ថាត: ឃើញគាត់ទៅបង្រៀនម្តង ។

ដារ៉ា: បង្រៀននៅឯណា?

ថាត: នៅបូរីកីឡានេះឯង ជាប់ស្តាតអូឡាំពិក មិនមានបូរីកីឡាម្ខាងទៀត ។

ដារ៉ា: បង្រៀនកងទ័ពឬបង្រៀនពីណា?

ថាត: នោះបង្រៀនតាមដូចថាមេៗ នៅតាមក្រសួងមន្ទីររបស់គេពីជំនាន់នោះឯងណា៎ ដូចថា ចាប់ពីអនុសេនាធំអី សេនាតូចតូចជាងគេ ។

ដារ៉ា: ចុះពូបានទៅចូលរៀន?

ថាត: ខ្ញុំទៅម្តង ។

ដារ៉ា: រៀនជាមួយ នួន ជា ហ្នឹង?

ថាត: បាទ ។

ដារ៉ា: រៀននៅឆ្នាំណា ខែណា?

ថាត៖ ៧៨ ចុងខែភ្លេច ។

ដារ៉ា៖ ចុះ អៀង សារី?

ថាត៖ អត់ទេ ឃើញតែតានួន ជា ហើយនិង ខៀវ សំផន ទេក្រៅពីនោះអត់បានឃើញទេ គ្រាន់តែបានឮឈ្មោះៗ ។

ដារ៉ា៖ ចុះកាលដែលពូរស់នៅក្នុងសម័យខ្មែរក្រហមនៅភ្នំពេញបណ្ដោយហ្នឹង ពូមានឮទាក់ទង នឹងគុកអីឈ្មោះអី ឈ្មោះអីខ្លះពូមានដឹងទេ?

ថាត៖ អត់ដឹងគេប្រធានគុក ប្រធានអី បានថាអត់ដឹងនៅម្ដុំកន្លែងខ្ញុំនៅទួលទំពូងនេះណា ខ្ញុំដឹងតាមពាក្យនេះដូចគេថាក្រៅផ្លូវការណ៍ក្នុងផ្លូវការណ៍ក៏បានកន្លែងនោះឯងដូច ថានេះផ្លូវយើងមានផ្លូវតូចមួយអ៊ំផ្លូវតូចអី ផ្លូវបែកពីក្បាលថ្នល់មកមិនមានផ្លូវដី ..តាមសេរីភាពមកផ្សារដើមគោរអិញ្ចេះមក នេះអានេះនៅម្ដុំខាងនេះឯង កន្លែងកៅស៊ូ នៅកន្លែងនេះឯងទៅខ្ញុំតែងធ្វើការមកចាក់ទឹកថ្នាំទឹកអី អាផ្ទះរផ្ទះតូចៗនេះឯងវាដាក់សន្តិសុខ២ ៣តំណពីលើនិយាយមិញនេះឯងវាប្រាប់វាអោយដឹងៗ តែវាដឹងតាមរយៈក្រសួងក៏មិនដឹង ថាអ្នកធំៗគេនៅកន្លែងហ្នឹង ដែលគេត្រូវចាប់ត្រូវអីណ៎ ថ្នាក់មេដឹកនាំ មេក្រសួងដែលគេត្រូវចាប់ក្បត់ក្ដីប្ដូក៏មេកងពលក្បត់អីគេយកទៅដាក់កន្លែងនោះមុនឯង ដើម្បីវាវាយសួរចំលើយយកឯកសារ...ចូលកន្លែងនោះឯងមុនដំបូងតាមស្ដាប់សូរណ៎វាយទាល់តែសន្លប់ សន្លប់ឈឺងទៅណ៎ពេទ្យដាក់ថ្នាំទៅវាដាក់ធ្វើអោយសរសេរ អោយសរសេរឯកសារអោយវា ។

ដារ៉ា៖ ដែលពូដឹង ដឹងតាមរយៈពីណាគេ?

ថាត៖ តាមរយៈអ្នកផ្ទះគេជាប់ទៅឮសូរថាកន្លែងអីដល់គ្នាឯងលួចខ្សិបអត់ដែលហ៊ាន ដេញដោយនិយាយពីរឿងរ៉ាវអីៗទេ ។

ដារ៉ា៖ ឈ្មោះមិត្ត រ៉ៃ ហ្នឹងនៅ?

ថាត៖ បាទ! នៅជាមួយខ្ញុំនេះឯង ។

ដារ៉ា៖ នៅរស់ទេ?

ថាត៖ បាទ! នៅរស់ទេ ។

ដារ៉ា៖ ឈ្មោះឥឡូវបច្ចុប្បន្នឈ្មោះអីដែរ?

ថាត៖ ឈ្មោះ ខាន់ៗ សួន ខាន់ នោះឯង ។

ដារ៉ា៖ ស្ងួន ខាន់?

ថាត៖ នោះឯង។ ធារិទ្ធ នោះឯងស្រឡាញ់វា ដូចថាទុកចិត្តណា៎ ទុកចិត្តទៅក្រោយទេ មិនទាន់ធ្វើការទេ គ្រាន់ថាគេទុកចិត្ត ធ្វើការអីទៅគេទុកចិត្តទៅ...ធ្វើការណានោះវាអាច ស្លាប់ដឹងនៅច្រើនណាស់នៅក្រោមណែនិយាយវាទូទាំងប្រទេស ប្រឡូកប្រឡំគ្នាមក នៅតាំងពីកំពង់ចាម កំពង់ធំដល់ខាងបាត់ដំបង គេនៅជុំគ្នាច្រើនណាស់ ចំរុះគ្នា អ្នកដែលនៅហ្នឹងទួលទំពូងហ្នឹង។

ដារ៉ា៖ សម្ភាសន៍ពូហូរហែរមកខ្ញុំមិនទាន់បានស្គាល់ឈ្មោះពូ ទេដោយសារខ្ញុំមិនចង់កាត់ពូណា៎ ពូឈ្មោះអីដែរ?

ថាត៖ ខ្ញុំឈ្មោះ ស៊ឹម ហោ តាំងពីកំណើត។

ដារ៉ា៖ ចុះឈ្មោះបដិវត្តន៍ពូឈ្មោះអី?

ថាត៖ ឈ្មោះថាត។

ដារ៉ា៖ ពូមានចាំឆ្នាំកំណើតទេ កើតឆ្នាំណា?

ថាត៖ ១៩៥៣។

ដារ៉ា៖ ហើយលោកពូស្រុកកំណើតកើតជាអី?

ថាត៖ នៅនេះឯង។

ដារ៉ា៖ ភូមិ?

ថាត៖ ត្រាច ភូមិកំពង់ចិន។ ហើយនេះបច្ចុប្បន្ននេះវាទៅជាកំពង់ចិនជើងដើមឡើយវាឃុំនេះវាជាឃុំតែមួយទេ ដល់មើលទៅវាច្រើន កាត់មួយខាងស្ទឹងទៅផ្សារអិញ្ចេះដាក់កំពង់ ចិនខាងជើង។

ដារ៉ា៖ ហើយលោកពូមានកូនចៅប៉ុន្មាននាក់ហើយរាល់ថ្ងៃហ្នឹង?

ថាត៖ ខ្ញុំកូន៦នាក់ ៤ប៉ុនអស់២។

ដារ៉ា៖ គ្រួសារលោកពូឈ្មោះអី ?

ថាត៖ ណែ៎ ព្រឹម យន។ ខ្ញុំទើបបានតែមកស្រុកទេ បានបានការ ការក្នុងឆ្នាំ៧៩ ចូល៨០ហើយ។ ឆ្នាំ៧៩មកដល់បានប៉ុន្មានខែនេះឯង បងប្អូនម៉ែឪនេះ ខ្ញុំមកដល់ ភ្លាមនោះបងថ្លៃខ្ញុំដែលខ្ញុំនិយាយនេះអោយខ្ញុំទៅចូលទ័ពវិញ ស្មោងនេះណា៎អោយខ្ញុំ ធ្វើពេទ្យ

ព្រោះខ្ញុំចេះអក្សរនាំ ហ្អែងទៅចូលធ្វើពេទ្យជាមួយអញទៅ កំពុងរកមនុស្សធ្វើពេទ្យមិនបានទេអាអ្នកចេះមើលថ្នាំមើលអី ខ្ញុំថាខ្ញុំប្រាប់បងឯង ខ្ញុំឈប់ធ្វើហើយមិនបាច់ មកលួងលោមខ្ញុំធ្វើនយោបាយរឿងសង្គ្រាមខ្ញុំឈប់ធ្វើហើយ ខ្ញុំដូចតំណាស់រស់ជាតិ សង្គ្រាមខ្ញុំឆ្អែតឆ្អន់ អែបអបនឹងស្គាល់អ្នកនេះនោះវាអត់ ជាមួយខ្មែរក្រហមដែលចាប់ខ្ញុំ ដូចណែដូច លោក ពីន យីន និយាយមិញនោះឆ្នាំ៩០ ៨៩-៩០ដែលខ្មែរក្រហម ចូលស្មោង២ដងដល់ចូលមកវាគិតដុតផ្ទះខ្ញុំមែន ខ្ញុំរត់ប្រជុំគ្នាទៅខ្ញុំ...ឯកសារអីខ្ញុំកប់ ចោលទាំងអស់ កាំភ្លើងអីៗខ្ញុំចូលមករត់ ដល់រត់មកវាចាប់ ចាប់បានបើថាចាប់ ខ្ញុំអត់បានខ្ញុំដែរសម្លាប់អាឃ្លាបមកឯងនេះយកមកពីរនាក់យកមកវាអត់ប្រជុំទេ វាយកទៅសារ៉ាយអីណោះទៅក្នុងភូមិ...យកទៅប្រជុំជាមួយមេកងពលវាអីណោះ ឈ្មោះ វុន ឥឡូវធ្វើកិច្ចសន្យាចាប់ពីថ្ងៃណោះ គេនៅគ្រប់គ្រងកណ្តែលហើយ គេអត់បាននៅឈរ ជើងកាន់កាប់ក៏ដោយនៅតែរដ្ឋកម្ពុជា ជីនាន់នោះនៅតែរដ្ឋកម្ពុជាទេណា បើសិនជាគេចូលម្តងទៀត បើសិនជាពួងឯងទាំងពីរនាក់នៅឈរឈ្មោះជាប្រធានភូមិទៀត អត់ពិបាកទេ ចាប់ហើយចុះកិច្ចសន្យាយាយតាចាស់ទុំទៅអង្វរសុំអូក្រេវគ្រាក់ទៅបានវា....ខ្ញុំ ព្រមព្រៀងថាមិនធ្វើទៀតទេ មិនធ្វើខ្ញុំដឹងហើយការវាលំបាកណាស់ កាលនោះយើងនៅសង្គ្រាម ដល់មកប្រជាជននេះវាអត់ដូចទ័ពទេវាខុសគ្នាណា ។ រឿងរបបយើងដែល យើងថាប្រជាធិបតេយ្យសេរីពហុបក្សនោះ របររកស៊ីធម្មតាទៅងាយណ៎ មិនមែនងាយ ដូចខ្មែរក្រហមចេញចូលបាយរបបអីណាអត់ទេ ។ អញ្ចេះគេមានសិទ្ធសេរីភាពដល់ អញ្ចេះទៅគេមកនៅគ្រប់គ្រងមួយរយៈក៏គេចាប់ផ្តើមបោះឆ្នោត ។

ដារ៉ា: អ្នកណាគេចាប់ផ្តើមបោះឆ្នោត?

ផាត: ខ្មែរក្រហមនេះឯងគេចូលមក គេអោយបណ្តាញគេបោះឆ្នោតរើសមេភូមិថ្មី ដល់រើសមេភូមិថ្មី គេអោយសរសេឈ្មោះទៅដូចថាឈរឈ្មោះជាបក្សជនអញ្ចេះណា ប្រជុំអញ្ចេះទៅក៏ឈរឈ្មោះគេបក្ខជន ប្រជាជននេះគេនៅតែអោយដាក់ខ្ញុំ ប៉ុន្មាន នាក់..វាអ្នកចាំមើលដល់វាចាំទទួលសំលេងឆ្នោតដល់បោះទៅបោះមកប្រជាជន វានៅតែបោះអោយក៏វាជាប់តែអាឯងដដែលនេះ ។ ក៏ដល់អញ្ចេះរាជរដ្ឋាភិបាលដែល ដេញ...ខ្មែរក្រហមមកវិញថា ខ្ញុំសុំច្បាប់ទៅហើយគ្នាពីរនាក់សរសេរលាលែងហើយ ថាអត់មានច្បាប់អីថា

អោយអ្នកឯងឈប់ទេ នៅតែធ្វើអិញ្ចេះម៉ង សួរថាឈប់អោយអ្នកណាអ្នកដឹកនាំ? មិនដឹងជាធ្វើយ៉ាងម៉េច ខ្ញុំថាខ្ញុំកំលាំងអន់ហើយខ្ញុំឈប់ធ្វើឈប់អី ហើយពិបាកណាស់ ។

ដាវ៉ាៈ អិញ្ចឹងរាល់ថ្ងៃពូនៅតែជាប្រធានភូមិដដែល?

ថាតៈ បាទ ខ្ញុំអិញ្ចេះពីមុនមកខ្ញុំជាអនុណា ដល់ពេលគេបោះឆ្នោតមេឃុំចៅសង្កាត់អិញ្ចេះទៅដល់លោក ទិន លាភ ឡើងជាចៅប្រឹក្សាឃុំទៅ បានជាខ្ញុំឡើងជាមេឃុំ ។

ដាវ៉ាៈ ទើបតែឡើងជាមេភូមិថ្មីៗហ្នឹងទេ?

ថាតៈ បាទ ។

ដាវ៉ាៈ មេភូមិត្រាច អិញ្ចឹងហ្ន៎?

ថាតៈ បាទ ។ បានថាវាដោះខ្លួនវាមិនរួចបានថាវាពិបាក ។ ប៉ុនថាអស់មួយអាណត្តិទៅ ក្រែងកូនចៅគេអ្នកក្រោយគេបានចេះដឹង ទុក...បើនិយាយទៅសព្វថ្ងៃវាចាស់ទៅ វានឹកឃើញថាវាមិនចង់បានតួនាទីតំណែងអីទេ គ្រាន់តែថាយើងនេះជាម៉ែជាឪសម្រាប់ ជាស្ពានចម្លងកូនចៅទេ អោយគេជាអ្នកជំនាន់ក្រោយទេដែលជាអ្នកកាន់កាប់នោះ ។

ដាវ៉ាៈ ចុះពូធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហម ៧៥-៧៩ពូតស៊ូតាំងពី៧២មក មិនអិញ្ចឹង? ហើយតស៊ូទៅបានចូលដល់ទីក្រុងភ្នំពេញហើយទៅបម្រើនៅទីក្រុងភ្នំពេញហ្នឹងទៀត ដូចថា ពូបានបម្រើខ្មែរក្រហមបានច្រើនឆ្នាំហើយណា ហើយពូយល់យ៉ាងម៉េចដែរចំពោះរបប ហ្នឹង?

ថាតៈ បើនិយាយ អានេះនិយាយតាមការពិចារណារបស់ខ្ញុំ មិនមែនលើកស្របតាមការ ឃោសនាឬក៏ការលើកឡើងរបស់ថ្នាក់ដឹកនាំបច្ចុប្បន្នរាជរដ្ឋាភិបាលឬក៏តាមសភា ដែលបានលើកឡើងពីការកាត់ទោសនៅក្នុងករណីកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ គ្រាន់ តែខ្ញុំយកខ្មែរក្រហមមកពិចារណាទៅ បើនិយាយទៅតាមគេហៅថាមតិច្បាប់ផ្លូវច្បាប់ វាត្រូវតែមានការកាត់ទោស ប៉ុន្តែក្នុងការកាត់ទោសនេះគឺខ្ញុំស្របតាមឯកភាពថាត្រង់ ចំនុចណាដែលជននោះឯងមិនព្រមដាក់ខ្លួននិងសារភាពចំពោះប្រជាពលរដ្ឋ ហើយមិនទទួល ស្គាល់កំហុសរបស់ខ្លួនដែលគេហៅថា បន្សល់ទុកនូវកម្មវេទនារបស់ប្រទេសដែលធ្លាក់ ទៅក្នុងគ្រោះមហន្តរាយអស់រយៈពេលច្រើនឆ្នាំ ។

ដាវ៉ាៈ ចុះពូមេដឹកនាំខ្មែរក្រហមច្រើនណាស់ ដូចខៀវ សំផន នួន ជា អៀង សារី អីមិនដែលទទួលស្គាល់ថាខ្លួនបានដឹកនាំប្រទេសមួយដែលធ្វើអោយមនុស្សស្លាប់ច្រើន បែរជា

ថាការសម្លាប់មនុស្ស ប្រជាជនស្លាប់អីទៅណា ថាមានអ្នកផ្សេងទេដែលធ្វើមិនមែនរបប ខ្មែរក្រហមទេ ។ ពូ ដែលពូធ្លាប់បំរើរបបខ្មែរក្រហម តើពូយល់យ៉ាងម៉េចដែរ?

ថាត: អានេះវា ខ្ញុំមិនអាចសន្និដ្ឋានកំណត់បានដែរ ព្រោះអាស្រ័យនៅលើគាត់ គាត់ឆ្លើយទៅតាមសំនួរថា អានេះយោងទៅតាមការដឹកនាំពីគេគេបញ្ជារមក ក៏ខ្ញុំមិនអាចសម្រេច ប៉ុន្តែខ្ញុំគ្រាន់តែយល់ថាអញ្ចេះ រាជរដ្ឋាភិបាលគេអត់អធ្យាស្រ័យទៅលើជំពូកជនណាដែលទទួលស្គាល់នូវការលើកឡើង អំពីនយោបាយរបស់ខ្មែរដែលវាត្រូវចុះចូលនិងសារភាពទេ គឺអាចលើកលែងទោសទៅតាមកំរិត តែចំពោះអ្នកដឹកនាំប្រទេសអោយអន្តរាយហើយមិនព្រមសារភាព អាហ្នឹងវាត្រូវតែមានការកាត់ទោស មិនអាចទុកបានទេ ។ បំណាច់ថាវាមានតែគេហើយ បើទុកវាមិនកើតព្រោះវា....មិនស្គាល់ពូជសាសន៍របស់ខ្លួនទៅហើយ ។ ប៉ុនមួយទៀតនោះមិនព្រមទទួលស្គាល់ក៏ថាបានក៏ប៉ុន្តែគ្រាន់តែថាវាក៏អត់ត្រូវដែរ បើតាមការពិចារណារបស់ខ្ញុំ...វាគ្រាន់តែទាក់ទិនទៅហ្នឹងអំពើប្រល័យពូជសាសន៍ បើថាឆ្លើយអោយផុតវាមិនអាចផុតទេ ប៉ុនគ្រាន់តែយើងនៅតែទទួលនូវឥទ្ធិពលការដាក់នាំនេះ ឯងវានៅតែមានវាមិនមែនអត់ទេ គ្រាន់តែថាមានអ្នកជាន់ខ្ពស់និងអ្នកបន្តបន្ទាប់ ក្រោមការដឹកនាំរបស់គេ ។

ដារ៉ា: ឥឡូវជាន់ខ្ពស់ម៉េចទៀត បើ នួន ជា អៀង សារី ខៀវ សំផន អីហើយមានខ្ពស់លើហ្នឹងទៀតអី?

ថាត: អេ៎ គ្រាន់តែ ប៉ុល ពត ជាប្រធានអីណ៎ អានេះខ្ញុំមិនអាចដឹងអារកិច្ចការងារគេនោះ ខ្ញុំគ្រាន់តែដឹងថា ឧទាហរណ៍ តាម៉ុក ដែលគេចាប់បាន ហើយគាត់មិនព្រមសារភាពទេលុះត្រាណាគេមិនចាប់បាន គាត់នៅតែមានបន្តសកម្មភាពរបស់គាត់ប្រមូល...កំលាំងរបស់គាត់ អញ្ចេះបើសិនជាបានវាត្រូវតែមានការកាត់ទោសហើយ តែអ្នកដ៏ទៃដែលនៅក្រោមទៀតក៏វាត្រូវតែកាត់តាមលំដាប់ លំដោយដែរ អាហ្នឹងបើតាមគំនិតរបស់ខ្ញុំ ។

ដារ៉ា: ហើយពូយល់ថាការកាត់ទោសហ្នឹងមានប្រយោជន៍អីដែរ?

ថាត: អានេះជាសារសំខាន់មួយនៅក្នុងប្រទេសឬក៏សង្គមឬក៏ជាតិសាសន៍ពូជសាសន៍ របស់ខ្មែរយើងតទៅអោយកូនចៅបានដឹងហើយយល់ថាកុំអោយមានអំពើនេះឯងតទៅទៀត ព្រោះអំពើនេះឯងធ្វើអោយខ្លួនឯងមិនបានសុខដុង ហើយក៏ធ្វើអោយប្រទេស នេះឯងវាអាច

លិចលង់ក្នុងកិច្ចការកសាងប្រទេសជាតិ ព្រោះគិតតាមដំហ៊ានលំដាប់ៗ ដូចថាមួយជំនាន់ៗមក យើងឃើញថាគេ...អ៊ីចឹងប្រទេសដែលគេជឿនលឿនគេដូចថា រឿងសង្គ្រាម គេឆាប់វិវឌ្ឍន៍លឿន គេឆាប់ស្របទៅតាមអ្នកដឹកនាំការកសាងប្រទេស របស់គេ.។

ដារ៉ា: ប៉ុន្តែពូយល់យ៉ាងម៉េចដែរ ការកាត់ទោសហ្នឹងដូចថាជាមេរៀនមួយអោយក្មេងជំនាន់ក្រោយអោយបានដឹងថាប្រទេសលិចលង់ទៅថ្ងៃក្រោយទៀត វាពន្យឺតនៃការកសាងជាតិ ប៉ុន្តែពូធ្លាប់បំរើក្នុងខ្មែរក្រហម តើពូយល់ឃើញថាជិវិតពូសោកស្តាយ ឬពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ថាត: សោកស្តាយមែនទែនបើសិនជាដឹងថាអាដែងហៅថាអំពើសោកនាដកម្មដល់ថ្នាក់នេះ មិនសមចូលរួមឡូកឡំជាមួយអំពើវាដែលឆ្លើយនេះមិនមែនហៅថាអោយរួចខ្លួនទេ កាលដែលចូលទៅយើងមិនដឹងហេតុផល ហើយម៉្យាងទៀតឧទាហរណ៍នៅទីក្រុងភ្នំពេញ ឬធ្វើទ័ពអិញ្ចេះទៅអត់ដឹងពីការកាប់សម្លាប់ដែលនៅខាងក្រោយនោះទេ បានថាខ្ញុំកាល នៅភ្នំពេញវាតែងបើកថាឆ្នាំនេះអោយខាងកំពង់ធំទៅលេងផ្ទះម្តង ដល់សភាពការអត់ ស្រួលវាអត់អោយមកវាថាចាំឆ្នាំ៧៩ទៅចាំអោយមកនេះយើងដឹងនឹងក្លួយខ្ញុំ កាលនោះត្រូវឈ្មោះខ្ញុំត្រូវបានមកលេងម្តងណា ដល់ដឹងសហករណ៍វាតឹងតែង...ពូអើយ ពូលើកឡើងនៅណោះសុទ្ធតែបាយ៣ពេលណ៎ យើងនៅនេះផងណ៎ទំរាំម៉ែឪយើងគាត់ អ្នកធ្វើស្រែធ្វើចំការផលដំណាំផ្សេងៗ មានភ្លឺមានប្រឡាយទឹកគេខ្វាត់ខ្វែងគេហូប ប៉ុន្មានពេល នេះវានិយាយអិញ្ចេះខ្ញុំដែលជាកូនជាចៅដែលទៅធ្វើការនៅក្នុងចង្កោម របបនេះឯងគ្មានដឹងហេតុផល ម៉ែយើង បងយើង ប្អូនយើងស្លាប់ដូចបានមកឃើញ ជាក់ស្តែងឯណា ន៎េះដល់ខ្ញុំត្រឡប់មកវិញទៅឃើញនៅម្តុំ...ឃើញអន្លង់ ឃើញរណ្តៅ ឃើញឆ្អឹង ក្បាលមនុស្សតូចធំ វាគួរអោយអណោចអធម៌ ខុសនេះខុសមិនធម្មតា នឹកឃើញស្តាយខ្លួន។

ដារ៉ា: ហើយចុះពូយល់យ៉ាងម៉េចដែរពេលពូត្រឡប់មកវិញឃើញបញ្ហាអិញ្ចឹងកើតឡើងណ៎ ដូចជា មានរណ្តៅសាកសព ការសម្លាប់មនុស្សអីអិញ្ចឹងពូយល់យ៉ាងម៉េចដែរ ដែលពូធ្លាប់បំរើខ្មែរក្រហមហ្នឹង?

ថាត: រឿងហ្នឹងដូចខ្ញុំបាននិយាយពីខាងដើមអិញ្ចេះឯង រឿងនេះខ្ញុំស្អប់ខ្ពើមជាទីបំផុត មិនអោយកើតឡើងទៀតទេ បានអិញ្ចេះខ្ញុំថា ដូចពេលបច្ចុប្បន្នអំពីហៅថាការផុសផុលអ្វីៗផ្សេងៗ

ដែលធ្វើអោយប្រទេសធ្លាក់ទៅក្នុងភក់សង្គ្រាមសារឡើងវិញគឺខ្ញុំស្អប់ខ្ពើម ខ្ញុំមិនចូលរួមទៀតទេ ។

ដារ៉ា: ហើយពូដែលនិយាយរឿងរ៉ាវហ្នឹងប្រាប់ប្រពន្ធកូនទេ?

ផាត: ប្រាប់ ហើយគេនៅនេះស្រាប់ផង គេដឹងពីប្រវត្តិដែលលំបាកលំបិនកុមារវែកអាចម៍គោអីៗយ៉ាងម៉េច អត់បាយក្រហាយទឹកអី វាដូចត់ណាស់ បើនិយាយខ្ញុំនៅជាមួយវាវិញ វាអោយខ្ញុំស៊ីត្រឹមត្រូវមែនណា៎ មិនមែននិយាយថាម៉េចទេ ។ ខ្ញុំនៅណោះខ្ញុំនិយាយហើយថា នៅក្រោយសហករណ៍ហើយ នៅមុខមិនសហជីបណា៎ ។ គេដាក់ថាកន្លែងសហជីប សហជីពកម្មករ ក្នុងមួយថ្ងៃ៣ពេល ហើយក្នុង៣ថ្ងៃគឺត្រូវអោយមានបន្ថែមម្តង ៣ពេលក្នុងមួយពេល មានម្ហូបពីរមុខទេណា៎និយាយអិញ្ចេះ ហើយវាអនុវត្តត្រឹមត្រូវមែន វាជានយោបាយរបស់វា អិញ្ចេះមីក្មួយខ្ញុំវានៅជាមួយខ្ញុំវាមកដល់វាទៅវិញ វារាយការណ៍ខ្ញុំខ្លោចចិត្តប៉ុនសួរថាអាចតទល់ជាមួយនឹងវាបើយើងអត់មានសិទ្ធសេរីភាពដូចបច្ចុប្បន្ននេះឯណា បានខ្ញុំថាអ៊ំគួរណាស់បញ្ហានេះ ព្រោះវាជូរវាល្វីងថា អោយកូនចៅជំនាន់ក្រោយកុំអោយទទួលស្គាល់នូវអ្វីដែលធ្វើអោយខ្លួនធ្លាក់ក្នុងរណ្តៅ ដែលជាគ្រោះមហន្តរាយដល់ប្រទេសជាតិហើយដល់ខ្លួនយើងទៀត ។ ថាវាបានឆ្លងកាត់ខ្លួនឯងហើយ កុំអោយកូនវាមានអិញ្ចេះឯងទៀតអោយវាបានសប្បាយហើយ វាបាន កសាងប្រទេសអោយបានជឿនលឿនទៅចុះខ្លួននោះវាបានដឹងហើយពីរស់ជាតិអាវាយ៉ាង ម៉េចដឹងអស់ហើយ ។

ដារ៉ា: អញ្ចឹងពូខ្ញុំអរគុណច្រើនដែលបានជួបផ្តល់ពត៌មានពូ ។

**ចប់**